- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៦ ក្រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងយុត្តិធម៌
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

**សំរេច**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

មាត្រា ១ .-

អនុក្រឹត្យនេះ មានគោលដៅកំណត់បែបបទ និង នីតិវិធី នៃការងារអត្រានុកូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ .-

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និង ស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ និង ដែលបង្កើតអោយជននោះមានសិទ្ធិ និងករណីយកិច្ច ។

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ និង ជនបរទេសដែលរស់នៅស្របច្បាប់ ក្នុងដែលសមត្ថកិច្ចកំណត់ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

សំបុត្រអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍និងសំបុត្រមរណភាព។

មាត្រា ៣ .-

ការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអត្រានុកូលដ្ឋានជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ គ្រប់រូប ។

មាត្រា ៤ .-

រាល់ការសុំចុះសៀវភៅអត្រានុកូលដ្ឋាន កំណើត និង មរណភាព អ្នករាយការណ៍ និង ឬ សាក្សី និង ឬ សាមីខ្លួនត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះការសុំចុះសៀវភៅអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ សាមីខ្លួន និង សាក្សី ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

មាត្រា ៥ .-

ទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយឯកភាពគ្នាទូទាំងប្រទេស ។ គំរូសំបុត្រអត្រានុកូលដ្ឋាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ៦ ._

ការចុះសៀវភៅអត្រានុកូលដ្ឋាន សម្រាប់ព្រះរាជវង្សានុវង្ស ត្រូវអនុវត្តដោយឡែក ដោយប្រគល់ភារកិច្ចនេះជូនរដ្ឋមន្ត្រីព្រះបរមរាជវាំង ។

មាត្រា ៧ ._

រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ ។

មន្ត្រីអត្រានុកូលដ្ឋាន មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងទេ ។

រាល់ការចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋាន មានចែងក្នុងជំពូកទី ១០ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## អំពីមន្ត្រីអត្រានុកូលដ្ឋាន

មាត្រា ៨ ._

មេឃុំ ឬ ចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនដីឃុំ ឬ សង្កាត់ ដែលខ្លួនគ្រប់គ្រង ។

នៅពេលដែលមេឃុំ ឬ ចៅសង្កាត់អវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរអោយជំទប់ ឬ ចៅសង្កាត់រង តាមឋានានុក្រម និង រាយការណ៍ជូនអភិបាលស្រុក ឬ ខណ្ឌតាមផ្លូវការ ។

ក្នុងករណីមេឃុំ ឬ ចៅសង្កាត់អវត្តមានដោយស្លាប់ ឬ ដោយបញ្ឈប់ពីមុខតំណែង ក្នុងចន្លោះពេលដែលមិនទាន់មានការរៀបចំមេឃុំ ឬ ចៅសង្កាត់ថ្មី សិទ្ធិជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់ជូនទៅ ជំទប់ ឬ ចៅសង្កាត់រង តាមឋានានុក្រម ។

មាត្រា ៩ ._

មន្ត្រីអត្រានុកូលដ្ឋានមានភារកិច្ច ៖

- ទទួលពិនិត្យ កត់ត្រា រឿងហេតុសំខាន់ៗទាក់ទងនឹង កំណើត អាពាហ៍ពិពាហ៍ មរណភាពនៃជនទាំងឡាយចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន
- ចេញសេចក្តីចម្លង ឬ សម្រង់ នៃអត្រានុកូលដ្ឋាន ដែលមានក្នុងឆ្នាំមិនទាន់ដាច់
- កែតម្រូវអក្ខរាវិរុទ្ធ លើអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ តាមលក្ខខណ្ឌមាត្រា ១៣ នៃអនុក្រឹត្យនេះ
- អនុញ្ញាតអោយរៀបអាពាហ៍ពិពាហ៍ និង ធ្វើបុណ្យបូជា ឬ បញ្ចុះសព
- ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋាន ដែលខ្លួនបានអនុវត្ត
- ចុះហត្ថលេខា និង បោះត្រា លើសំបុត្រអត្រានុកូលដ្ឋាន
- កែតម្រូវ ឬ បដិសេធអត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬ តាមបទប្បញ្ញត្តិ នៃច្បាប់

-ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទអោយបានគង់វង្សល្អ ងាយស្រួលក្នុងការតាមដាន និងការគ្រប់គ្រង

-បញ្ជូនសៀវភៅអត្រានុកូលដ្ឋានឆ្នាំដែលដាច់ទៅ យកទៅតម្កល់ទុកនៅសាលាស្រុក ឬ ខណ្ឌផ្ទាល់ ០១ ច្បាប់ និងនៅតុលាការខេត្ត ឬ ក្រុងសាមី ០១ ច្បាប់

-ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ ឬ សង្កាត់ អោយបានយល់ដឹងអំពីកាតព្វកិច្ចរបស់ខ្លួនចំពោះអត្រានុកូលដ្ឋាន និង បង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ដែលមកទំនាក់ទំនងអំពីអត្រានុកូលដ្ឋាន

-ធ្វើរបាយការណ៍អំពី កំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ ឬ សង្កាត់ជារៀងរាល់ខែ និង រាល់ដំណាច់ឆ្នាំនីមួយៗ ផ្ញើទៅសាលាស្រុក ឬ សាលាខណ្ឌសាមី

-សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន អំពីការងារអត្រានុកូលដ្ឋានក្នុងករណីចាំបាច់ ។

មាត្រា ១០ ._

រាល់ការអនុវត្តនីការងារអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋានដូចការងារ អត្រានុកូលដ្ឋាន ដែលអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ដោយប្រកាសរួម ។

មាត្រា ១១ ._

ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានមន្ត្រី ០១ រូប នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល អោយទទួលមុខងារជាមន្ត្រីអត្រានុកូលដ្ឋាន តាមសេចក្តីសំរេចចាត់តាំងពីរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដោយជូនពត៌មានទៅ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

បែបបទនៃការបំពេញមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននេះ ត្រូវពិគ្រោះរវាងក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

## ជំពូកទី ៣
## អំពីសៀវភៅអត្រានុកូលដ្ឋាន

មាត្រា ១២ ._

ក្នុងឃុំ ឬ សង្កាត់នីមួយៗ ត្រូវមានសៀវភៅអត្រានុកូលដ្ឋាន សម្រាប់កត់ត្រាអំពីកំណើតអាពាហ៍ពិពាហ៍មរណភាព បញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និង បញ្ជាក់មរណភាព ។

សៀវភៅនេះត្រូវធ្វើជា ០២ ច្បាប់ដូចគ្នា តាមប្រភេទនីមួយៗ តាមគំរូដែលកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សៀវភៅនេះត្រូវចុះចំនួនសន្លឹក និង ចុះលេខរៀងសន្លឹក ពីសន្លឹកទី១ ដល់សន្លឹកចុងក្រោយ ។ សន្លឹកទី១ និងសន្លឹកចុងក្រោយត្រូវសរសេរជាអក្សរ និង ត្រូវចុះហត្ថលេខាពេញដោយអភិបាលស្រុក ឬ អភិបាលខណ្ឌ ។ សន្លឹកទី២ និង សន្លឹកដទៃទៀតអាចចុះហត្ថលេខាសង្ខេប និងបោះត្រារបស់អភិបាល ស្រុក ឬ អភិបាលខណ្ឌគ្រប់សន្លឹក ។

មាត្រា ១៣ ._

សៀវភៅអត្រានុកូលដ្ឋានទាំងអស់ មិនត្រូវអោយមាន កោស ឆូត លុប សរសេរជ្រៀតថែមឡើយ ។ បើមានកោស ឆូត លុប ត្រូវទុកពាក្យអោយទាំងនោះនៅមើលបាន ហើយសរសេរទឹកខ្មៅពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងថា យល់ព្រមលុបប៉ុន្មានពាក្យ និង យល់ព្រមថែមប៉ុន្មានពាក្យ ទើបមន្ត្រីអត្រានុកូលដ្ឋាន អ្នករាយការណ៍ និង ឬសាក្សី និង ឬ សាមីខ្លួនចុះហត្ថលេខា ឬ ផ្តិតមេដៃស្តាំទាំងអស់ គ្នា ។

ចំពោះសន្លឹកណា ដែលសរសេរខុស ត្រូវរក្សាទុកជាឯកសារមិនអោយហែកចោលឡើយ ។

មាត្រា ១៤ ._

សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗ ត្រូវបើកអោយប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ មករា ហើយត្រូវបញ្ឈប់នៅថ្ងៃទី ៣១ ខែ ធ្នូ រៀងរាល់ឆ្នាំ ។

នៅខែមករាឆ្នាំបន្ទាប់ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបញ្ជូនសៀវភៅតាមប្រភេទនីមួយៗ ០១ ច្បាប់ទៅសាលាស្រុក ឬ ខណ្ឌសាមី ដើម្បីត្រួតពិនិត្យ និង តម្កល់ទុកនៅទីនោះ និង បញ្ជូន ០១ ច្បាប់ទៀត ដែលដូចគ្នាទៅតម្កល់ទុកនៅតុលាការខេត្ត ឬ ក្រុងសាមី ដើម្បីមុខការតាមផ្លូវ ច្បាប់ ។

សៀវភៅអត្រានុកូលដ្ឋាន ដែលបានប្រើប្រាស់នៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវបញ្ជូនតាមរយៈក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នៅខែ មករា ឆ្នាំ បន្ទាប់ មកតម្កល់ទុក ០១ ច្បាប់ នៅក្រសួងមហាផ្ទៃ និង ០១ ច្បាប់ទៀតតម្កល់ទុកនៅក្រសួងយុត្តិធម៌ ។

មាត្រា ១៥ ._

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរៀបចំទុកដាក់ ថែរក្សាសៀវភៅអត្រានុកូលដ្ឋាន និង សំណុំឯកសារដែលពាក់ព័ន្ធការងារអត្រានុកូលដ្ឋានអោយបានល្អ និង រក្សាការសម្ងាត់របស់បុគ្គលម្នាក់ៗ ។

ចំពោះសាលាឃុំ ឬ សង្កាត់ណា ដែលមិនធានាសុវត្ថិភាព មន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ ឬ សង្កាត់នោះ ត្រូវផ្ញើសៀវភៅអត្រានុកូលដ្ឋានទៅរក្សាទុកនៅសាលាស្រុក ឬ ខណ្ឌសាមី ។ ពេលធ្វើអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាននោះត្រូវទៅធ្វើនៅសាលាស្រុក ឬ ខណ្ឌ ទៅតាមបែបបទដូចបានអនុវត្ត នៅសាលាឃុំ ឬ សង្កាត់ ។

មាត្រា ១៦ .-

ក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំសៀវភៅអត្រានុកូលដ្ឋានអោយបានឯកភាពទូទាំងប្រទេស និង បណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាន អំពីរបៀបកត់ត្រាចូលក្នុងសៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទនីមួយៗ និង ធានាផ្គត់ផ្គង់សៀវភៅ និង សំបុត្រអត្រានុកូលដ្ឋានអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់មន្ត្រីអត្រានុកូលដ្ឋាន ។

## ជំពូកទី ៤
## អំពីសំបុត្រកំណើត

មាត្រា ១៧ .-

បើមានទារកកើត ឪពុក ឬ ម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ ឬ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយទារកនោះ មិនអោយហួស៣០ថ្ងៃ ដោយបញ្ជាក់អោយបានច្បាស់ថា ឪពុកនិងម្តាយនៃទារកនោះមានខាន់ស្លា ឬ ឥតខាន់ស្លា ។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុក និង ម្តាយទារកនោះ ។

បើឪពុក ម្តាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្តាន ឬ អ្នកនៅជិតខាងដែលបានឃើញ និងដឹងឮផ្ទាល់ពីទារកនោះកើតអោយទៅចុះសៀវភៅកំណើតអោយបានទាន់ពេលកំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និងម្តាយទារកនោះជាប់ទៅជាមួយផង ។

មាត្រា ១៨ .-

នាមត្រកូលរបស់ទារក អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយ ឬ អាចយកឈ្មោះជីតាខាងឪពុក ឬ អាចយកឈ្មោះឪពុករបស់ទារកនោះក៏បាន ។

ឪពុក ម្តាយ ឬ អាណាព្យាបាល ជាអ្នកដាក់នាមខ្លួនអោយទារក ។

មាត្រា ១៩ .-

បើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់អោយមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬ សង្កាត់នៃទីកន្លែងដែលរើសទារកនោះ ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុ និង ចុះក្នុងសៀវភៅកំណើត ដោយរកឈ្មោះដាក់អោយ ហើយបើក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំ កំណើតទារកដែលរើសបាននោះ ដោយស្មាន និង ឈ្មោះឪពុកម្តាយដាក់ថាមិនស្គាល់ ។

បើមានជនណា សុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ ។

ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះ ធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកដែលរើសបាននោះ ទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់ទារកនោះ និង កំណត់ហេតុស្ដីអំពីការប្រគល់ទារកនោះ ជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ។

មាត្រា ២០ .-

ចំពោះទារក ឬ កុមារ ដែលកំពុងចិញ្ចឹមបីបាច់ថែរក្សា ក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ហើយដែលពុំទាន់មានសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតអ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះត្រូវធ្វើសេចក្ដីរាយការណ៍ និង នាំទារក ឬ កុមារនោះទៅជូនមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមជ្ឈមណ្ឌលនោះតាំងនៅ ដើម្បីមន្ត្រីអត្រានុកូលដ្ឋានផ្ដល់សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតអោយ ។

មាត្រា ២១ .-

ការសុំទារក ឬ កុមារ ពីមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ការសុំទារកដែលរើសបាន និងការសុំទារក ឬ កូនពីឪពុក ម្ដាយធ្វើជាកូនចិញ្ចឹម ត្រូវអនុវត្តទៅតាមនីតិវិធី ដូចមានចែងក្នុងច្បាប់ និង លិខិតបទដ្ឋានជាធរមាន ។

កិច្ចសន្យាសុំកូនខាងលើនេះ ត្រូវចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន ។

មាត្រា ២២ .-

បើមានទណ្ឌិតណាម្នាក់សម្រាលកូន ទីកន្លែងកំណើតនៃទារកនោះ ត្រូវយកតាមលំនៅដ្ឋានរបស់ម្ដាយ ឬ ឪពុក ។

មាត្រា ២៣ .-

ទារកកើត ឪពុកម្ដាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងសៀវភៅកំណើតដែរ ។ នៅពេលធ្វើសំបុត្រកំណើត បើឪពុកម្ដាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះបានឆ្លើយទទួលស្គាល់ដោយជាក់លាក់ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក ម្ដាយនោះថាជាឪពុក ម្ដាយរបស់កូននោះ ។

ករណីមានតែឪពុក ឬ មានតែម្ដាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូនរបស់អ្នកដែលបានទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ ។

ក្រោយពេលឪពុក ឬ ម្ដាយបានប្ដឹងចុះក្នុងសៀវភៅកំណើត ឪពុកឬ ម្ដាយណា ដែលមិនទាន់ទទួលស្គាល់ទារកនោះ ឪពុក ឬ ម្ដាយនោះ អាចប្ដឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

កូនឥតខាន់ស្លាដែលឪពុក ម្ដាយបានទទួលស្គាល់ នឹង ទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពីកំណើតកូននោះ ឪពុក ម្ដាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នា នឹង ពេលចុះអាពាហ៍ពិពាហ៍ ឬ ក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

មាត្រា ២៤ ._

ក្រោយពេលចុះសៀវភៅកំណើតរួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់អោយអ្នករាយការណ៍នូវសំបុត្រកំណើតច្បាប់ដើម ០១ សន្លឹកទុកជាសម្គាល់ និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

មាត្រា ២៥ ._

បើមានទារកកើតហើយ ទុកអោយហួសរយៈពេល ៣០ ថ្ងៃ ពុំបានទៅរាយការណ៍ ចុះសៀវភៅកំណើត ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី ។ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលទារកនោះ ត្រូវយកសាលក្រមតុលាការនោះមកសុំមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅ ដើម្បីចុះសៀវភៅកំណើត ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ។

មាត្រា ២៦ ._

ទារកកើតពីម្តាយ ឪពុកជាពលរដ្ឋខ្មែរ រស់នៅស្របច្បាប់ឯបរទេស ឬ ពីឪពុកជាពលរដ្ឋខ្មែរម្តាយជាជនបរទេស ពីឪពុកជាជនបរទេស ម្តាយជាពលរដ្ឋខ្មែរ ឪពុក ម្តាយ នៃទារកនោះអាចសុំចុះ សៀវភៅកំណើតនៅឯប្រទេសនោះ តាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ ។ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវទៅចុះសៀវភៅកំណើតនៅឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅតាមសំបុត្រកំណើតដែលប្រទេសនោះចេញអោយ ដោយយកសញ្ជាតិតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវយកសំបុត្រកំណើតថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅ នូវសំបុត្រកំណើតថ្មីអោយយកទៅប្រើប្រាស់ ។

បើឪពុក ម្តាយនៃទារកនោះ បានទៅរាយការណ៍ចុះសៀវភៅកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ អាចយកសំបុត្រកំណើតដែលប្រគល់អោយនោះមកពីប្រើប្រាស់ជាផ្លូវការបាន ។

មាត្រា ២៧ ._

ជនអន្តោប្រវេសន៍ និង ជនបរទេស ដែលបានរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បានកើតទារកនៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ឪពុក ម្តាយទារកនោះ អាចទៅចុះ

សៀវភៅកំណើតនៅសាលាឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់ ឬ អាចទៅចុះសៀវភៅកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។ បើចុះសៀវភៅកំណើតនៅសាលាឃុំ សាលាសង្កាត់ នាមត្រកូល និង នាមផ្ទាល់ខ្លួន និងនាមនៃឪពុក ម្តាយរបស់ទារកនោះ ត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរខ្មែរផង ។

ចំពោះសញ្ជាតិនៃកូននោះ ត្រូវអនុវត្តតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៥

## អំពីសំបុត្រអាពាហ៍ពិពាហ៍

**មាត្រា ២៨ ._**

បុរស នារី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យអោយបានហ្មត់ចត់នូវពាក្យសុំនោះ ដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់ ស្តីពីការអាពាហ៍ពិពាហ៍ និង គ្រួសារ ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៩ ._**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងធ្វើនោះ ផ្សាយជាសាធារណៈ នៅលំនៅដ្ឋាន និង នៅសាលាឃុំ ឬ សាលាសង្កាត់ នៃសាមីខ្លួននារី ០១ ច្បាប់ ។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ០២ច្បាប់ទៀតត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និង បិទនៅសាលាឃុំ ឬ សង្កាត់នៃសាមីខ្លួនបុរស ០១ ច្បាប់ ។

ប័ណ្ណប្រកាសត្រូវចុះ ៖

១-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅនៃអនាគត ប្តី ប្រពន្ធ ។

២-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅរបស់ ឪពុក ម្តាយ នៃអនាគត ប្តី ប្រពន្ធ បើឪពុក ឬ ម្តាយស្លាប់ ត្រូវដាក់ថាស្លាប់ ។

៣-រយៈពេលប្តឹងជំទាស់

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីជនដែលមានផលប្រយោជន៍ក្នុងរឿងនេះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ ។ ផុតរយៈពេល១០ថ្ងៃ អាពាហ៍

ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្ដឹងជំទាស់ ។ បើមានបណ្ដឹងជំទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្ដឹងជំទាស់ត្រូវបានសមត្ថកិច្ចដោះស្រាយចប់ ។

មាត្រា ៣០ ._

អាពាហ៍ពិពាហ៍ នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារីដែលស្ម័គ្រចិត្តទទួលគ្នាជា ប្ដី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់នារី ។

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខា ដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្ដិតមេដៃ ប្ដី ប្រពន្ធ និង សាក្សីគ្រប់អាយុការចំនួន ០២នាក់ផង ។

មាត្រា ៣១ ._

ពេលសាមីខ្លួនជាអនាគត ប្ដី និង ប្រពន្ធ មករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់អោយសាមីខ្លួន ប្ដីប្រពន្ធ នូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និងចេញសេចក្ដីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

មាត្រា ៣២ ._

ការសុំរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ និង ជនបរទេស ដែលរស់នៅស្រុកបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេស ដែលគូភាគីមានទីលំនៅ ។

ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ និង អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ត្រូវទទួលស្គាល់យកជាការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនផ្ទុយនឹងបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬ សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះ ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេស នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ឬ បើប្ដី ប្រពន្ធមកតាំងលំនៅនៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកចុះ សៀវភៅអាពាហ៍ពិពាហ៍ នៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនបានរស់នៅ ។ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល ឬ មន្ត្រីអត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ថតចម្លងផ្លូវការនោះទុកហើយចម្លងចេញពីសៀវភៅនូវសំបុត្រអាពាហ៍ពិពាហ៍ថ្មី អោយទៅជននោះយកទៅប្រើប្រាស់ ។

មាត្រា ៣៣ ._

អាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និង ជនបរទេស ឬ ជនអន្តោប្រវេសន៍ ដែលរស់នៅស្របច្បាប់ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣៤ ._

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬ ជនអន្តោប្រវេសន៍នោះបាន ដោយអនុវត្តតាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ ដែលមានចែងនៅក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋាន ដោយប្រាប់ពីទីកន្លែង និងពេលវេលាដែលខ្លួនរៀបអាពាហ៍ពិពាហ៍នេះអោយបានច្បាស់ ។

ពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចទៅសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ឬសុំចុះសៀវភៅអាពាហ៍ពិពាហ៍ នៅមន្ត្រីអត្រានុកូលដ្ឋានតាមច្បាប់ព្រះរាជាណាចក្រកម្ពុជាក៏បាន ។

ការចុះឈ្មោះនៃជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

## ជំពូកទី៦

## អំពីសំបុត្រមរណភាព

មាត្រា ៣៥ ._

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកមានភារកិច្ចនៅក្រសួងស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬ សង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់ ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតអោយធ្វើបុណ្យបូជា ឬ បញ្ចុះសព បើស្លាប់ដោយជម្ងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬ ដោយគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទង ដល់អំពើឃាតកម្ម នៃបទល្មើសឧក្រិដ្ឋណាមួយ ។

ការចុះសៀវភៅមរណភាព និង ចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព ។

បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាត អាចបណ្តាលអោយគ្រោះថ្នាក់ដល់សង្គម ត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬ ផ្នែកអនាម័យភ្លាម ។ បើពេទ្យ ឬ ផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតឯនុញ្ញាអោយធ្វើបុណ្យបូជា ឬ បញ្ចុះសពតាមការសម្រេចនោះ ។

មាត្រា ៣៦ ._

បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យដល់អំពើឃាតកម្ម នៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬ ជនទាំងឡាយណា ដែលមានការពាក់ព័ន្ធត្រូវរាយការណ៍ភ្លាម ដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកនោះស្លាប់ ដើម្បីអោយសមត្ថកិច្ចជំនាញនានាពិនិត្យស្រាវជ្រាវ និងដោះស្រាយរួសរាន់ ។ ក្រោយពីមានការសម្រេចយ៉ាងណាពីភ្នាក់ងារមានសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតអោយធ្វើបុណ្យបូជា ឬ បញ្ចុះសពបាន ។

មាត្រា ៣៧ ._

បើមានពលខ្មែររស់នៅក្នុងឃុំ ឬ សង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬ សង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់ ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់របស់អ្នកស្លាប់រស់នៅ ដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់អោយទៅយកសពធ្វើបុណ្យ និង ចុះសៀវភៅមរណភាពនៅឃុំ ឬ សង្កាត់នៃអ្នកស្លាប់នោះស្នាក់នៅជាប់លាប់ ។

បើអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬ គ្មានអ្នកសាប់ស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់ដែលមានអ្នកស្លាប់ត្រូវចាត់ចែងបូជា ឬ បញ្ចុះសពនោះ និង ចុះសៀវភៅមរណភាពក្នុងឃុំ ឬ សង្កាត់នោះ ។

មាត្រា ៣៨ ._

បើមានអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ អ្នកទទួលខុសត្រូវនៃពន្ធនាគារនោះ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងទៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅអចិន្ត្រៃយ៍របស់អ្នកទោសនោះ ដើម្បីមន្ត្រីអត្រានុកូលដ្ឋានចុះក្នុងសៀវភៅមរណភាព ។

មាត្រា ៣៩ ._

ពេលមានអ្នករាយការណ៍អំពីមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅមរណភាពរួចប្រគល់អោយអ្នកសុំនូវសំបុត្រមរណភាពច្បាប់ដើម ០១ សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

មាត្រា ៤០ ._

បើមានអ្នកស្លាប់ទុកអោយហួសរយៈពេល ១៥ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត-ក្រុងសាមី រួចយកសាលក្រម

តុលាការនោះមកសុំមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅមរណភាព ។

មាត្រា ៤១ ._

បើមានពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេសបានស្លាប់ ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកដែលបានឃើញអ្នកស្លាប់នោះផ្ទាល់ អាចទៅចុះសៀវភៅមរណភាពនៅប្រទេសនោះ តាមច្បាប់របស់ប្រទេសនោះ ។ ពេលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាព ដែលធ្វើនៅបរទេសនោះទៅចុះសៀវភៅនៅ ឃុំ ឬ សង្កាត់ ដែលសាមីខ្លួនអ្នកស្លាប់ ធ្លាប់ស្នាក់នៅជាប់ លាប់មុនចេញទៅបរទេស ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវដកយកសំបុត្រមរណភាពផតចម្លងជាផ្លូវការទុកជាឯកសារ ពេកចម្លងចេញពីសៀវភៅមរណភាពនូវសំបុត្រមរណភាពថ្មី ប្រគល់អោយសាមីខ្លួនអ្នកសុំយកទៅប្រើប្រាស់ ។

បើបានទៅរាយការណ៍ចុះសៀវភៅមរណភាពនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ រួចហើយពេលត្រឡប់មកប្រទេសកម្ពុជាវិញ អាចយកសំបុត្រមរណភាពនោះមកប្រើប្រាស់ជាផ្លូវការបាន ។

មាត្រា ៤២ ._

ជនអន្តោប្រវេសន៍ និង ជនបរទេសរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានស្លាប់នៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬ អ្នកទទួលខុសត្រូវ អាចទៅចុះសៀវភៅមរណភាពនៅសាលាឃុំ ឬ សង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់មុនពេលខ្លួនស្លាប់ ឬ អាចទៅចុះសៀវភៅមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ។

បើចុះសៀវភៅមរណភាពនៅឃុំ ឬ សង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរខ្មែរផង ។

## ជំពូកទី៧

## អំពីសំបុត្របញ្ជាក់កំណើត

មាត្រា ៤៣ ._

ពលរដ្ឋខ្មែរដែលបានកើតមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះសៀវភៅបញ្ជាក់កំណើតបាន តាមគំរូពែលនាំថ្មី

នៅសាលាឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២ រូប ជានីតិជននិងជាមនុស្សគួរអោយជឿទុកចិត្តបាន ដែលបានស្គាល់ច្បាស់ពីប្រវត្តិអ្នកត្រូវសុំធ្វើសំបុត្របញ្ជាក់កំណើត និង ធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយ ពីពេលដែលសាមីខ្លួនកើត នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬ ទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬ សោធននិវត្តន៍ ឬ សេចក្តីបញ្ជាក់ពីស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះនៅក្នុងសៀវភៅបញ្ជាក់កំណើតមិនត្រូវអោយខុសពីថ្ងៃខែកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬ សោធននិវត្តន៍ជាផ្លូវការឡើយ ។

មាត្រា ៩៤ .-

ពេលមានអ្នកមកសុំចុះសៀវភៅបញ្ជាក់កំណើត មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់កំណើត រួចត្រូវប្រគល់អោយសាមីខ្លួន ឬ ក្រុមគ្រួសារនូវសំបុត្របញ្ជាក់កំណើតច្បាប់ដើម ០១ សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ។

## ជំពូកទី៨
## អំពីសំបុត្រកញ្ជាក់អាពាហ៍ពិពាហ៍

មាត្រា ៩៥ .-

ពលរដ្ឋខ្មែរដែលបានគ្នាជាប្តី ឬ ប្រពន្ធពិតប្រាកដ នៅមុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយគ្មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនប្តី ប្រពន្ធអាចមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅជាប់លាប់ បច្ចុប្បន្នដោយមានសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរអោយជឿទុកចិត្តបាន ដែលបានដឹងច្បាស់ពីសាមីខ្លួនប្តី ប្រពន្ធនោះនិងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយគ្នា នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

មាត្រា ៩៦ .-

ពេលមានសាមីខ្លួនប្តី និង ប្រពន្ធមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់អោយសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្របញ្ជាក់ អាពាហ៍ពិពាហ៍ច្បាប់ដើម ០១ សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ។

## ជំពូកទី៩
## អំពីសំបុត្របញ្ជាក់មរណភាព

**មាត្រា ៤៧ .-**

ពលរដ្ឋខ្មែរ ដែលស្លាប់មុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមានហើយ គ្មានសំបុត្រមរណភាព សាច់ញាតិសន្តានដែលនៅរស់ អាចមកសុំចុះសៀវភៅបញ្ជាក់មរណភាព គំរូណែនាំនាំថ្មីនៅសាលាឃុំ ឬ សង្កាត់ ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្នបាន ដោយនាំសាក្សីចំនួន ០២ រូប ជានីតិជន និង ជាមនុស្សគួរអោយជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់អំពីការស្លាប់ និង ធ្លាប់ រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយអ្នកស្លាប់មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៤៨ .-**

ពេលមានអ្នកមកសុំចុះសៀវភៅបញ្ជាក់មរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់មរណភាព រួចត្រូវប្រគល់អោយអ្នកមកសុំនូវសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ០១សន្លឹក និងចេញ សេចក្តីចម្លងតាមការស្នើសុំ ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ។

## ជំពូកទី១០
## អំពីសេចក្តីចម្លង ឬ សម្រង់អត្រានុកូលដ្ឋាន

**មាត្រា ៤៩ .-**

សេចក្តីចម្លង ឬ សម្រង់អត្រានុកូលដ្ឋានមាន សេចក្តីចម្លង ឬ សម្រង់សំបុត្រកំណើត សេចក្តីចម្លង ឬ សម្រង់សំបុត្រអាពាហ៍ពិពាហ៍ សេចក្តីចម្លង ឬ សម្រង់សំបុត្រមរណភាព សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់កំណើត សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ និង សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់មរណភាព ។

រាល់ខ្លឹមសារនៃសេចក្តីចម្លង ត្រូវអនុវត្តដូចគ្នានឹងខ្លឹមសារក្នុងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ។ សម្រង់អត្រានុកូលដ្ឋាន ត្រូវធ្វើតាមសំណើរបស់អ្នកសុំដោយដកស្រង់នូវខ្លឹមសារសំខាន់ៗ ចេញពីសៀវភៅអត្រានុកូលដ្ឋាន ។

**មាត្រា ៥០ .-**

បើមានអ្នកមកសុំចម្លង ឬ សុំស្រង់សំបុត្រអត្រានុកូលដ្ឋានពីមន្ត្រីអត្រានុកូលដ្ឋាន អ្នកសុំត្រូវមានសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមយកមកជាមួយ តែការចម្លង ឬ សម្រង់ត្រូវស្រង់ចេញពីសៀវភៅដែលតម្កល់ទុក ។ ក្នុងករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មន្ត្រីអត្រា

នុកូលដ្ឋានត្រូវចម្លងតាមសៀវភៅអត្រានុកូលដ្ឋាន ដែលបានចុះពីមុនមក និង កំពុងថែរក្សាក្នុងឆ្នាំដែលមិនទាន់ផុត នៅសាលាឃុំ ឬ សាលាសង្កាត់ ។ ក្នុងករណីសៀវភៅអត្រានុកូលដ្ឋានបានវិនាសដោយមានកំណត់ហេតុត្រឹមត្រូវ ហើយមានសេចក្ដីណែនាំពីអន្តរក្រសួង ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ទើបធ្វើការចម្លង ឬ សម្រង់ចេញពីសន្លឹកអត្រានុកូលដ្ឋាន ដែលសាមីខ្លួនអ្នកសុំមាន ហើយយកទៅប្រើការបាន ។

មាត្រា ៥១._

ការសុំចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ផុត ត្រូវសុំចម្លង ឬ សុំស្រង់ នៅសាលាឃុំ ឬ សាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាល ស្រុក ឬ ខណ្ឌ និង បោះត្រាផង ។

មាត្រា ៥២ ._

ការសុំចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬ សុំស្រង់នៅសាលាស្រុក ឬ ខណ្ឌ ឬ នៅតុលាការខេត្ត ក្រុងសាមី ។

ការសុំចម្លង ឬ សម្រង់នៅសាលាស្រុក ឬ សាលាខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និង ត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាលស្រុក ឬ ខណ្ឌ និង បោះត្រាផង ។

ការសុំចម្លង ឬ សម្រង់នៅតុលាការខេត្ត ក្រុងត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និង ត្រូវបញ្ជាក់ហត្ថលេខានោះដោយប្រធានតុលាការ ឬ ចៅក្រមជំនួស និង បោះត្រាផង ។

មាត្រា ៥៣ ._

ពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ការសុំចម្លង ឬ សម្រង់អត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ផុត ត្រូវសុំចម្លង ឬ សុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬ កុងស៊ុល និង បោះត្រាផង ។

ការសុំចម្លង ឬ សម្រង់អត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវសុំចម្លង ឬ សុំស្រង់នៅក្រសួងមហាផ្ទៃ ឬនៅក្រសួងយុត្តិធម៌ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ តម្កល់ទុកនៅទីនោះ ។

## ជំពូកទី១១
## អំពីការទទួលខុសត្រូវចំពោះមុខច្បាប់
## ស្ដីពីការងារអត្រានុកូលដ្ឋាន

**មាត្រា ៥៤ ._**

សាមីខ្លួន និង ឬអ្នករាយការណ៍ និង ឬ សាក្សី ត្រូវសំដែងនូវការស្មោះត្រង់ ចំពោះការបញ្ជាក់អះអាងរបស់ខ្លួនអំពីហេតុការណ៍ដែលកើតមានឡើង ហើយដែលខ្លួនបានដឹងឮ ឬ ឃើញផ្ទាល់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្ដីពីអត្រានុកូលដ្ឋានតាមប្រភេទ ។

**មាត្រា ៥៥ ._**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ។ បើមានមន្ត្រីអត្រានុកូលដ្ឋានណាម្នាក់ការឃុបឃិត ឬ ក្លែងបន្លំដោយចេតនា ក្នុងការធ្វើសំបុត្រអត្រានុកូលដ្ឋាន ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

សំបុត្រអត្រានុកូលដ្ឋានក្លែងបន្លំដែលបានចេញរួចហើយ ត្រូវប្រមូលយកទៅវិញ នឹងប្ដឹងទៅតុលាការដើម្បីបដិសេធ និង សំរេចផ្ដន្ទាទោសតាមច្បាប់ ។

## ជំពូកទី១២
## អំពីថវិកា អត្រានុកូលដ្ឋាន

**មាត្រា ៥៦ ._**

ការបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និង ការបណ្ដុះបណ្ដាល អំពីការងារអត្រានុកូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេសត្រូវស្ថិតក្នុងបន្ទុកថវិការដ្ឋ ។

**មាត្រា ៥៧ ._**

ក្រសួងមហាផ្ទៃត្រូវលើកគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ការសំបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងការបណ្ដុះបណ្ដាលការងារអត្រានុកូលដ្ឋាន ។

**មាត្រា ៥៨ ._**

ការសុំចុះសំបុត្រអត្រានុកូលដ្ឋាន កំណើត និង មរណភាព អ្នកមកសុំមិនតម្រូវអោយបង់ថ្លៃអ្វីឡើយ ។

ការសុំច្បាប់រៀបអាពាហ៍ពិពាហ៍ និង ការចុះសំបុត្រអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ ការសុំមញ្ញាក់កំណើតបញ្ជាក់អាពាហ៍ពិពាហ៍ និង បញ្ជាក់មរណភាព អ្នកសុំត្រូវបង់ថ្លៃក្រដាសតាមការកំណត់ ។

រាល់ការសុំចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋានអ្នកមកសុំត្រូវបង់ថ្លៃក្រដាស និងថ្លៃបិទតែមប្រិ៍ ដើម្បីជាប្រយោជន៍សម្រាប់ ឃុំ ឬ សង្កាត់ និង ចំណូលថវិការដ្ឋ ។

ថ្ងៃប្រកាសអត្រានុកូលដ្ឋាន និង ថ្ងៃតែមប្រើត្រូវកំណត់ដោយអនុក្រឹត្យ តាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី១៣

## អន្តរប្បញ្ញត្តិ

មាត្រា ៥៩ .‗

ការសុំបញ្ជាក់អត្រានុកូលដ្ឋានមានចុះ សៀវភៅបញ្ជាក់កំណើត សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ហើយអនុវត្តតែក្នុងរយៈពេល៣ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។ ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋាន កំណើត និង មរណភាព ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុមសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន ។ ឯការបញ្ជាក់ អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍អនុញ្ញាតអោយប្តីងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

មាត្រា ៦០ .‗

ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនរបស់ជនណាម្នាក់ផ្សេងទៀត ។

មាត្រា ៦១ .‗

រាល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ចាស់ ដែលមានស្រាប់ពីសង្គមមុនៗ និង អត្រានុកូលដ្ឋានក្រោយឆ្នាំ ១៩៧៩ ហើយរក្សាទុករហូតដល់បច្ចុប្បន្ន សាមីខ្លួនត្រូវយកមកបង្ហាញមន្ត្រីអត្រានុកូលដ្ឋានបច្ចុប្បន្ន ដើម្បីចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន តាមគំរូថ្មី សម្រាប់ប្រើប្រាស់ទៅថ្ងៃក្រោយ ។

មាត្រា ៦២ .‗

ក្នុងករណីដែលពិនិត្យសំបុត្រអត្រានុកូលដ្ឋានចាស់ពី មុនណាមួយដែលមានលក្ខណៈពុំត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រមូលសំបុត្រអត្រានុកូលដ្ឋានមកវិញ រួចណែនាំអោយសាមីជនបំពេញបែបបទនោះមកវិញ រួចណែនាំអោយសាមីជនបំពេញបែបបទសុំអត្រានុកូលដ្ឋានថ្មី ។

មាត្រា ៦៣ .‗

ហាមមនុស្សម្នាក់ចុះសៀវភៅអត្រានុកូលដ្ឋានក្នុងប្រភេទនីមួយៗ លើសពី ០១ដង និង នៅច្រើនកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី១៤

## អំពីទោសប្បញ្ញត្តិ

មាត្រា ៦៤ .‗

ជនណារាយការណ៍មិនពិត អំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬ យកអត្រានុកូលដ្ឋានរបស់អ្នកដទៃទៅប្រើប្រាស់ជារបស់ខ្លួន ឬ រាយការណ៍សុំចុះអត្រានុកូលដ្ឋាន លើស

ពី០១ដង នៅទីកន្លែងដដែល ឬ ទីកន្លែងផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ប្រើប្រាស់អត្រានុកូលដ្ឋានក្លែង ត្រូវពិន័យ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

មាត្រា ៦៥ ._

មន្ត្រីអត្រានុកូលដ្ឋានណា សមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានអោយប្រជាពលរដ្ឋដែលមកសុំ ឬ បានទារប្រាក់លើសច្បាប់កំណត់ពីប្រជាពលរដ្ឋសម្រាប់ការងារអត្រានុកូលដ្ឋាន ត្រូវពិន័យជាប្រាក់ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

## ជំពូកទី១៥

## អវសានប្បញ្ញត្តិ

មាត្រា ៦៦ ._

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦៧ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

| សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| ស ខេង | យូ ហុកគ្រី | អ៊ុក វិធុន |

***

## អនុក្រឹត្យលេខ ៥២១ អនក្រ.តត

## ស្តីពីការជូនមេដាយ សហមេត្រី

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយ សេនា សហមេត្រី ជូនលោក វរសេនីយ៍ឯក **Dougall Mc Millan** សេនានុពន្ធអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អ ក្នុងការលើកស្ទួយទំនាក់ទំនង មិត្តភាព និងកិច្ចសហប្រតិបត្តិការល្អ រវាងប្រទេសទាំងពីរ កម្ពុជា អូស្ត្រាលី ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៤២២ អនក្រ.តត

## ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា ១ ._** ត្រូវបានប្រគល់ មេដាយ ស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ១៩ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសាលាបឋមសិក្សាបែកចាន និង សាលប្រជុំ សាលាស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមាននាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ឯកឧត្តម ចេព ខន | ថវិកា ចំនួន | ១២.០០០ USD |
| ២-ឯកឧត្តម គន់ គីម | ថវិកា ចំនួន | ១០.០០០ USD |
| ៣-ឯកឧត្តម សួន សិទ្ធី | ថវិកា ចំនួន | ១០.០០០ USD |
| ៤-ឯកឧត្តម អ៊ឹក ចាន់ | ថវិកា ចំនួន | ១៥.០០០ USD |
| ៥-ចាន់ អ៊ូ សំអួន | ថវិកា ចំនួន | ១០.០០០ USD |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-លោក អ៊ិន ឃុន | ថវិកា ចំនួន | ៥.០០០ USD |
| ២-លោក ឈុន សុគាត | ថវិកា ចំនួន | ៥.០០០ USD |
| ៣-លោក អ៊ុំ សាក់ | ថវិកា ចំនួន | ៥.០០០ USD |
| ៤-លោក មិន គឹមសាន | ថវិកា ចំនួន | ៥.០០០ USD |

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-លោក ជូ សុជាតិ | ថវិកា ចំនួន | ២.០០០ USD |
| ២-លោក យឹម ទីរិទ្ធ | ថវិកា ចំនួន | ២.០០០ USD |
| ៣-លោក មិន គី | ថវិកា ចំនួន | ២.០០០ USD |
| ៤-លោក លី ទឡ្ហនា | ថវិកា ចំនួន | ២.០០០ USD |
| ៥-លោក ទិញ នី | ថវិកា ចំនួន | ២.០០០ USD |

**មាត្រា ២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ៩២៣ អនក្រ.តត
## ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តបាត់ដំបង

## សំរេច

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយមាស ស្ថាបនាជាតិ ជូនតំណាងអង្គការមណ្ឌលមេត្តាករុណា ០២ រូប ដែលបានចូលរួមយ៉ាងសកម្ម និងបរិច្ចាគថវិកាក្នុងការជួយស្តារអភិវឌ្ឍន៍ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ចំណាយអស់ទឹកប្រាក់សរុប ចំនួន ១៩២.៧៩៧ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ៖

១-លោកស្រី ដា នី (DANI)

២-លោកស្រី សេ ស៊ីល (CECIL)

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

# អនុក្រឹត្យលេខ ៩២៤ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងទេសចរណ៍
- យោងតាមសំណើរបស់ក្រសួងទេសចរណ៍

**សំរេច**

**មាត្រា ១ ._** តែងតាំងលោក **ញឹម ខេមរា** ជាប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ ។

**មាត្រា ២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤២៥ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងទេសចរណ៍

- យោងតាមសំណើរបស់ក្រសួងទេសចរណ៍

**សំរេច**

មាត្រា ១ ._ តែងតាំង :

១-លោក សៅ សារឿន អធិការ

២-លោក ចាន់ គន្ធី ជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌

៣-លោក អ៊ិន ឈឿន ជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន

នៃក្រសួងទេសចរណ៍ ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៤២៦ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសុខាភិបាល
- យោងតាមសំណើរបស់ក្រសួងសុខាភិបាល

**សំរេច**

មាត្រា ១ ._ តែងតាំងលោក សោម សារ៉ន ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងសុខាភិបាល ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៩២៧ អនក្រ.តត

## ស្តីពីការជូនមេដាយការងារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ក្រសួងទេសចរណ៍

## សំរេច

មាត្រា ១ ._ ត្រូវប្រគល់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីបច្ចេកទេសនៃក្រសួងទេសចរណ៍ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ជំនាញទេសចរណ៍ដូចមានរាយនាមខាងក្រោម នេះ ៖

ក-មេដាយមាសការងារ ៖

១-លោកជំទាវ ប៉ាន់ ចំណាន នាយកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី

២-លោក ជុំ ប៉ារីសុត អធិការ ( ចូលនិវត្តន៍ )

៣-លោក រស់ សំអ៊ា ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍

៤-លោក ប៉ាក់ សុខុម ប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍

៥-លោក យ៉ង់ ទ័ន ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍

៦-លោក ញឹម ខេមរា ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

៧-លោក ឌួង ទីរៈ អនុប្រធាននាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ ទទួលបន្ទុកការងារគ្រប់គ្រងបុគ្គលិក

ខ-មេដាយប្រាក់ការងារ :

១-លោក រ៉ិត ចាន់ថា ប្រធាននាយកដ្ឋានអប់រំ និងបណ្តុះបណ្តាល

២-លោក ឆៃ គឹមហុង នាយខុទ្ទកាល័យរងកខុត្តមរដ្ឋមន្ត្រី

៣-លោក សៅ សារឿន អធិការរង

៤-លោក ឌិត ចន្ថា អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍

៥-លោក អ៊ុក សុខា អនុប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ

៦-លោក អ៊ី ឃីម អនុប្រធាននាយកដ្ឋាន ឧស្សាហកម្មទេសចរណ៍

៧-លោក កែន សាគុណ អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌

៨-លោក សយ សាខន អធិការរង

៩-លោក ហោ សារុន អនុប្រធាននាយកដ្ឋានអប់រំ និងបណ្តុះបណ្តាល

១០-លោក អ៊ុក ស៊ីផាន អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍

១១-លោក អ៊ិន ចឿន អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍

១២-លោក តេង ហ៊ុយ ប្រធានមន្ទីរទេសចរណ៍ក្រុងព្រះសីហនុ

១៣-លោក គោស៊ី សារឿត ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប

១៤-លោក ជង់ ឡឹម ប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ

១៥-លោក ណែម ស៊ីនួន ប្រធានមន្ទីរទេសចរណ៍ខេត្តកំពត

១៦-លោក ញ៉ុទ សុខ ប្រធានមន្ទីរទេសចរណ៍ខេត្តពោធិសាត់

១៧-លោក ហ៊ិន សារឿន ប្រធានមន្ទីរទេសចរណ៍ខេត្តតាកែវ

១៨-លោក ម៉ុង យ៉េន ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ចាម

១៩-លោក ចិន សាម៉ន អនុប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ

២០-លោក ពៅ សុខន អនុប្រធានមន្ទីរទេសចរណ៍ខេត្តកណ្តាល

គ-មេដាយសំរឹទ្ធការងារ :

១-លោក កើត ពុទ្ធទី អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍

២-លោក ចាន់ តក្កី អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌

៣-លោក សួង ម៉េងឡុង អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍

៤-លោក អៀ ម៉ុងដេង ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ

៥-លោក ម៉ិន មៀច ប្រធានមន្ទីរទេសចរណ៍ខេត្តកោះកុង

៦-លោក ត្រា នុតស៊ាន ប្រធានមន្ទីរទេសចរណ៍ខេត្តរតនគិរី

៧-លោក អ៊ុន ឃួន ប្រធានមន្ទីរទេសចរណ៍ខេត្តស្វាយរៀង
៨-លោក ស៊ីវ រុន ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ឆ្នាំង
៩-លោក អេង ប៊ុក់ ប្រធានមន្ទីរទេសចរណ៍ខេត្តព្រៃវែង
១០-លោក ឯល ណារី អនុប្រធានមន្ទីរទេសចរណ៍ក្រុងកែប
១១-លោក ផៃ ដារ៉ាឫទ្ធី ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ធំ
១២-លោក ការ៉ន រិទ្ធី ប្រធានមន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ
១៣-លោក ចន សំជីន ប្រធានមន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី
១៤-លោក ម៉ម រដ្ឋា អនុប្រធានមន្ទីរទេសចរណ៍ខេត្តស្ទឹងត្រែង
១៥-អ្នកស្រី អ៊ឹម សាទី ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
១៦-លោក ម៉ក់ ស៊ីណាង៉ា ប្រធានការិយាល័យរដ្ឋបាល ហិរញ្ញវត្ថុ មន្ទីរទេសចរណ៍ខេត្តបាត់ដំបង
១៧-លោក ម៉្រុក សាម៉ន អនុប្រធានមន្ទីរទេសចរណ៍ខេត្តតាកែវ

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៩២៨ អនក្រ.តត**

**ស្ដីពីការជូនមេដាយ សុវត្ថារា**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ក្រសួងទេសចរណ៍

**សំរេច**

មាត្រា ១ ._ ត្រូវប្រគល់ មេដាយ ធិបឌិន្ឌ សុទត្ថារា ជូនមន្ត្រីថ្នាក់ដឹកនាំក្រសួងទេសចរណ៍ ០៥ រូប ដែលមានស្នាដៃល្អ ក្នុងការដឹកនាំវិស័យទេសចរណ៍ មានការរីកចំរើន ដូចមានរាយនាមខាងក្រោមនេះ ៖

១-ឯកឧត្តម នុត និនឿន រដ្ឋលេខាធិការ

២-ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការ

៣-ឯកឧត្តម សំ ព្រហ្មនា អនុរដ្ឋលេខាធិការ

៤-ឯកឧត្តម សេ ផែន អនុរដ្ឋលេខាធិការ

៥-ឯកឧត្តម សូ ម៉ារ៉ា អគ្គនាយក

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

***

## ២-សេចក្តីសំរេច

### សេចក្តីសំរេចលេខ ៦៧ សសរ

### ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សំរាប់ការងារស្តារ និងបូមដីតាមដងទន្លេ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញសេចក្តីសំរេចលេខ ២៥ សសរ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សំរាប់ការងារស្តារ និងបូមដីតាមដងទន្លេ
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួង សំរាប់ការងារស្តារ និងបូមដីតាមដងទន្លេ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | លឹម គានហោ | រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | ប្រធាន |
| ២-ឯកឧត្តម | នី យ៉ាំង | រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៣-ឯកឧត្តម | ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៤-ឯកឧត្តម | ម៉ៅ សំអឿន | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥-ឯកឧត្តម | ស៊ិន នីនី | អនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | សមាជិក |
| ៦-ឯកឧត្តម | ត្រាក់ ថៃសៀង | អភិបាលរងរាជធានីភ្នំពេញ | សមាជិក |
| ៧-ឯកឧត្តម | ឡូយ សុផាត | អភិបាលខេត្តក្រចេះ | សមាជិក |
| ៨-ឯកឧត្តម | ជៀង អំ | អភិបាលខេត្តកំពង់ចាម | សមាជិក |
| ៩-ឯកឧត្តម | ឆេត ឧន្នី | អភិបាលខេត្តកណ្តាល | សមាជិក |
| ១០-ឯកឧត្តម | ម៉ិន ហ៊ាន | អគ្គនាយកកិច្ចការបច្ចេកទេស សមាជិកអចិន្ត្រៃយ៍ | សមាជិក |

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះមានភារកិច្ច :

១-ធ្វើការសិក្សា ពិនិត្យ ពិចារណា និងលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យសំរេចរាល់បញ្ហាដែលពាក់ព័ន្ធនឹងការងារស្តារ និងបូមដីតាមដងទន្លេ ។

២-រួមសហការណែនាំតាមបណ្តាផ្នែកនៃក្រសួងពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្តីសំរេចទាំងឡាយរបស់រាជរដ្ឋាភិបាល ស្តីពីការងារស្តារនិងបូមដីតាមដងទន្លេ ។

៣-ពង្រឹងសហប្រតិបត្តិការជាមួយបណ្តាប្រទេសផ្តល់ជំនួយ និងអង្គការអន្តរជាតិនានាក្នុងការពិភាក្សាពិចារណាការសិក្សា និង អភិវឌ្ឍន៍ការងារស្តារទន្លេក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤-ធ្វើទំនាក់ទំនងសំរបសំរួលជាមួយបណ្តាសហគមន៍ផ្តល់ជំនួយអន្តរជាតិ ដើម្បីស្វែងរកទុនជំរុញការសិក្សា និងអភិវឌ្ឍន៍គំរោងអោយបានទាន់ពេលវេលា និងមានប្រសិទ្ធិភាពខ្ពស់ ។

៥-ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលយ៉ាងតិច ១ ឆ្នាំ ម្តង ។

ប្រការ ៣ : គណៈកម្មការនេះមានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួនតាមការចាំបាច់ ដើម្បីជំនួយការ ។ គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់របស់ក្រសួងធនធានទឹកនិងឧតុនិយម ក្នុងការអនុវត្តន៍ភារកិច្ចពាក់ព័ន្ធ ចាំបាច់ ។

ប្រការ ៤ : គណៈកម្មការអន្តរក្រសួងនេះ មានទីស្នាក់ការស្ថិតនៅទីស្តីការក្រសួងធនធានទឹក និងឧតុនិយម ។

ប្រការ ៥ : សមាជិកគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ប្រធានគណៈកម្មការអាចនឹងអញ្ជើញតំណាងអាជ្ញាធរដែនដីខេត្ត ក្រុងដែលពាក់ព័ន្ធ ចូលរួមប្រជុំបាន ។

ប្រការ ៦ : សេចក្តីសំរេចលេខ ២៤ សសរ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សំរាប់ការងារស្តារ បូមដីតាមដងទន្លេ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីខេត្ត ក្រុងដែលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ , ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

## III-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០០

**ប្រកាសលេខ ១០៤៥ ឧរថប២.ប្រក**

**ស្តីអំពី**

**ស្តង់ដារឧស្សាហកម្មកម្ពុជា CS 001-2000**

**"ការបិទស្លាកផលិតផលចំណីអាហារ"**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.ប្រក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ. ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យគុណភាព ផលិតផលឧស្សាហកម្ម-សិប្បកម្ម
- បានឃើញប្រកាសលេខ ៩៦៣ នប.ប្រក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការចុះបញ្ជីផលិតផលឧស្សាហកម្ម របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- យោងតាមស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ន

**សំរេច**

**ប្រការ ១ :** បង្កើតស្តង់ដារឧស្សាហកម្មកម្ពុជា CS 001-2000 ស្តីពី **ការបិទស្លាកផលិតផលចំណីអាហារ** សំរាប់អនុវត្ត ចំពោះការបិទស្លាកលើរាល់ផលិតផលចំណីអាហារ ដែលបានវេចខ្ចប់ជាមុន សំរាប់ផ្តល់ជូនអតិថិជន ឬសំរាប់គោលបំណងផ្គត់ផ្គង់ជាចំណីអាហារ និងចំពោះរាល់ ទិដ្ឋភាពដែលមានទាក់ទងដល់ការបង្ហាញលើស្លាកនោះ ។

**ប្រការ ២ :** រាល់ក្រុមហ៊ុនរោងចក្រ សហគ្រាស និងសិប្បកម្មទាំងអស់ ត្រូវប្រតិបត្តិការបិទស្លាកលើរាល់ផលិតផលចំណីអាហារតាមស្តង់ដារ CS 001-2000 ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ជូនភ្ជាប់មកជាមួយ ។

**ប្រការ ៣ :** ប្រកាស ឬសេចក្តីសំរេចណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ស៊ុយ សែម

ឧបសម្ព័ន្ធ

ស្តង់ដារ ឧស្សាហកម្មកម្ពុជា

CS 001-2000

# ការបិទស្លាកលើផលិតផលចំណីអាហារ

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ឆ្នាំ ២០០០

# បុព្វកថា

ដើម្បីព្រះរាជាណាចក្រកម្ពុជាទទួលបាននូវសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង និង អភិវឌ្ឍន៍លើវិស័យឧស្សាហកម្ម និងបំពេញបន្ថែមនូវសក្តានុពលដ៏បរិបូរណ៍ដល់ផ្នែកសេដ្ឋកិច្ចទីផ្សារសេរី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានបង្កើតការិយាល័យស្តង់ដារឧស្សាហកម្មកម្ពុជា ដែលហៅកាត់ថា "សឧក" (Industrial Standards Bureau of Cambodia - ISC) ក្នុងគោលបំណងរៀបចំចងក្រងស្តង់ដារជាតិ និងធ្វើសហប្រតិបត្តិការជាមួយអង្គភាពស្តង់ដារនានាក្នុងប្រទេស និងក្រៅប្រទេសរួមមានអង្គការស្តង់ដារតំបន់ និង អង្គការស្តង់ដារអន្តរជាតិ ISO ។ ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិករបស់អង្គការស្តង់ដារអន្តរជាតិ -International Organization for Standardization (ISO) ចាប់តាំងពីថ្ងៃ ០១-០១-១៩៩៥ មក ។ ការចងក្រងជាឯកសារស្តង់ដារឧស្សាហកម្មនេះ គឺជាភារកិច្ចចាំបាច់មួយក្នុងចំណោមភារកិច្ចស្នូលទាំងឡាយរបស់ក្រសួងឱស្សាហកម្ម រ៉ែ និងថាមពល ក្នុងដំណាក់កាលដែលព្រះរាជាណាចក្រកម្ពុជា បានជាសមាជិកនៃសមាគមអាស៊ាន ដើម្បីផ្តល់ការងារស្រួលដល់ការធ្វើចរាចរទំនិញជាសកល និងបង្កើនប្រសិទ្ធភាពគុណភាពផលិតផល ដែលនឹងនាំមកនូវកំណើនជាប្រចាំលើផលិតភាពរបស់មូលដ្ឋានផលិតកម្ម ដោយទទួលបាននូវវិសាលភាពពាណិជ្ជកម្ម បង្កលក្ខណៈងាយស្រួល នឹងឆ្លើយតបតាមតម្រូវការរបស់អ្នកប្រើប្រាស់ដោយផ្តល់ភាពវិជ្ជមានដល់សុខុមាលភាពសាធារណៈ ។

ការិយាល័យស្តង់ដារឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានរៀបចំចងក្រងនូវស្តង់ដារអំពីការបិទស្លាកលើផលិតផលចំណីអាហារនេះឡើង គឺសំរាប់ផលិតករនៅក្នុងប្រទេសកម្ពុជាយកទៅប្រើប្រាស់តាមគោលបំណង និងតំរូវការនៃមុខទំនិញ ដែលជាផលិតផលចំណីអាហារ ។

ឯកសារស្តង់ដារ អំពីការបិទស្លាកលើផលិតផលចំណីអាហារនេះ បានរៀបចំឡើងដោយបានយោងទៅតាមស្តង់ដារអន្តរជាតិ និងយោងតាមការស្រាវជ្រាវលើតំរូវការជាក់ស្តែង និងបទពិសោធន៍ដែលមានកន្លងមកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

# ការបិទស្លាកលើផលិតផលចំណីអាហារ

# CS 001-2000

**១.វិសាលភាព :**

ស្តង់ដារនេះ សំរាប់អនុវត្តចំពោះការបិទស្លាកលើរាល់ផលិតផលចំណីអាហារ ដែលបានវេចខ្ចប់ជាមុន ដើម្បីផ្តល់ឱ្យអតិថិជន ឬ ដើម្បីបំណងផ្គត់ផ្គង់ជាម្ហូបអាហារ និង ចំពោះរាល់ទិដ្ឋភាពពិត ដែលមានទាក់ទងដល់ការបង្ហាញលើស្លាកនោះ ។

**២.និយមន័យនៃវាក្យសព្ទប្រើក្នុងស្តង់ដារនេះ :**

- **អ្នកប្រើប្រាស់ :** មានន័យថា ជាបុគ្គល ឬក្រុមណាមួយដែលទិញ ឬទទួលចំណីអាហារ ដើម្បីបំពេញទៅតាមសេចក្តីត្រូវការផ្ទាល់ខ្លួន ។
- **សំបកវេចខ្ចប :** មានន័យថា ជាសំភារៈប្រើសំរាប់វេចខ្ចប់ចំណីអាហារ ដើម្បីសំរួលក្នុងការដឹកជញ្ជូន និងការថែរក្សា ទោះបីជាមានការវេចខ្ចប់ជាដុំ ឬដោយឡែកៗក៏ដោយ ហើយក៏អាចរាប់បញ្ចូលទាំងសំបកក្រដាស ឬប្លាស្ទិករុំពីក្រៅផងដែរ ។

សំបកវេចខ្ចប់ អាចខ្ចប់ប្រមូលផ្តុំគ្រប់មុខ ឬតាមប្រភេទនៃកញ្ចប់សំរាប់អ្នកប្រើប្រាស់ ។

- **កាលបរិច្ឆេទនៃការការផលិត :** មានន័យថា កាលបរិច្ឆេទ នៅពេលដែលចំណីអាហារបានក្លាយទៅជាផលិតផល ។
- **កាលបរិច្ឆេទនៃការវេចខ្ចប់ :** មានន័យថា កាលបរិច្ឆេទ នៅពេលដែលចំណីអាហារត្រូវបានដាក់ភ្លាមៗទៅក្នុងសំបកវេចខ្ចប់ ហើយនឹងត្រូវលក់នៅទីបំផុត ។
- **កាលបរិច្ឆេទផុតកំណត់ :** មានន័យថា កាលបរិច្ឆេទដែលបង្ហាញនូវរយៈពេលចុងក្រោយ ដែលបានគ្រោងទុកក្រោមលក្ខខ័ណ្ឌនៃការរក្សាទុក ដែលបន្ទាប់ពីពេលនោះផលិតផលទំនងជានឹងពុំមានគុណភាព ។ បន្ទាប់ពីកាលបរិច្ឆេទនេះ ចំណីអាហារនឹងមិនអនុញ្ញាតឱ្យលក់នៅលើទីផ្សារឡើយ ។
- **កាលបរិច្ឆេទនៃរយៈកាលអប្បបរមា :** "ល្អបំផុតបើប្រើមុន" មានន័យថា កាលបរិច្ឆេទដែលប្រាប់ឱ្យដឹងនូវថេរវេលាចុងក្រោយ ក្រោមលក្ខខ័ណ្ឌបញ្ជាក់ណាមួយក្នុងពេលដែល

ផលិតផលអាចចរាចរពេញលេញលើទីផ្សារបាន ហើយគុណភាពជាក់លាក់ណាមួយនៅរក្សាបាន សំរាប់ការកាត់យល់ ឬការអះអាងដែលបានធ្វើឡើង ។ ទោះជាយ៉ាងណាក៏ដោយ ក្រោយកាលបរិច្ឆេទនេះ ចំណីអាហារនៅតែអាចប្រើប្រាស់បាន ។

- **ចំណីអាហារ :** មានន័យថា រាល់សារធាតុ មិនថាជាផលិតផលសំរេច ផលិតផលពាក់កណ្តាលសំរេច ឬនៅឆៅ ដែលមានបំណងសំរាប់ប្រើប្រាស់ក្នុងការបរិភោគរបស់មនុស្សដោយរាប់បញ្ចូល ទឹកសំរាប់ផឹក ស្ករកៅស៊ូ និងរាល់សារធាតុ ដែលត្រូវបានគេប្រើក្នុងការផលិត ការរៀបចំ ឬប្រព្រឹត្តិកម្មនៃចំណីអាហារ ប៉ុន្តែមិនរាប់បញ្ចូលគ្រឿងសំអាងថ្នាំជក់ ឬសារធាតុប្រើជាឱសថឡើយ ។

- **គ្រឿងបន្ថែមលើចំណីអាហារ :** មានន័យថា សារធាតុទាំងឡាយដែលមិនប្រើប្រាស់ដោយផ្ទាល់ជាចំណីអាហារធម្មតា និងមិនត្រូវប្រើប្រាស់ជាប្រភេទគ្រឿងផ្សំក្នុងចំណីអាហារឡើយ ទោះជាវាមាន ឬ គ្មានសារៈប្រយោជន៍ជាអាហារូបត្ថម្ភក៏ដោយ ការបន្ថែមដោយចេតនានូវគ្រឿងបន្ថែមទៅលើចំណីអាហារ គឺសំរាប់តែគោលបំណងបំរើបច្ចេកវិជ្ជាក្នុងការផលិត (រាប់បញ្ចូលទាំងការបំរើអារម្មណ៍) វិធីផលិតការរៀបចំប្រព្រឹត្តិកម្ម ការរៀបចំវេចខ្ចប់ ការវេចខ្ចប់ ការដឹកជញ្ជូន ឬការរក្សាដល់គុណភាពចុងក្រោយនៃចំណីអាហារ ។ លក្ខខ័ណ្ឌនេះមិនរាប់បញ្ចូលនូវសារធាតុដែលធ្វើឱ្យក្រខ្វក់ ឬចំលងមេរោគ ឬ សារធាតុដែលត្រូវបន្ថែមលើចំណីអាហារសំរាប់ការថែរក្សា ឬបង្កើនគុណភាពអាហារូបត្ថម្ភឡើយ ។

- **គ្រឿងផ្សំ :** មានន័យថា សារធាតុឱ្យរួមទាំងគ្រឿងបន្ថែមលើចំណីអាហារផ្សេងៗ សំរាប់ប្រើក្នុងការផលិត ឬការផ្សំចំណីអាហារមួយដែលវាមានវត្តមាននៅក្នុងផលិតផលសំរេច ទោះបីជាវាអាចធ្វើឱ្យផ្លាស់ប្តូរទ្រង់ទ្រាយក៏ដោយ ។

- **ស្លាក :** មានន័យថា ផ្លាក ម៉ាក រូបភាព ឬ ជាលក្ខណៈពិពណ៌នាផ្សេងៗ ដែលគេបានសរសេរ ឬបោះពុម្ព ឬធ្វើជាចំណាំ ឬធ្វើឱ្យផ្តិតជាប់ ឬចងភ្ជាប់ទៅនឹងសំបកវេចខ្ចប់ចំណីអាហារ ។

- **ការធ្វើស្លាក :** គិតបញ្ចូលទាំងអ្វីៗដែលបានសរសេរ បោះពុម្ព ឬជាក្រាហ្វិក ដែលបានបង្ហាញនៅលើស្លាកផលិតផល ទៅតាមចរិតពិតរបស់ចំណីអាហារ ឬបានដាក់បង្ហាញនៅជិតចំណីអាហារគិតទាំងអ្វីដែលសំរាប់បំរើការផ្សាយលក់ផងដែរ ។
- **លេខឡូត៍ :** មានន័យថា បរិមាណកំណត់នៃផលិតផលមួយ ដែលត្រូវបានផលិតជាចាំបាច់នៅក្រោមលក្ខខ័ណ្ឌតែមួយដូចគ្នា ។
- **ការវេចខ្ចប់ជាមុន :** មានន័យថា បានវេចខ្ចប់ ឬបានធ្វើឡើងជាមុននៅក្នុងសំបកវេចខ្ចប់សំរាប់ផ្ទុកបំរុង ដើម្បីបញ្ជូនទៅឱ្យអតិថិជន ឬដើម្បីគោលបំណងសំរាប់ចែកចាយ ។
- **គ្រឿងជំនួយផលិតកម្ម :** មានន័យថា សារធាតុ ឬសំភារៈដែលមិនរាប់បញ្ចូលនូវបរិធាន ឬឧបករណ៍ទាំងឡាយ ហើយក៏មិនប្រើប្រាស់ ដូចជាគ្រឿងចំណីអាហារដែរ គឺមានបំណងប្រើក្នុងផលិតកម្មនៃវត្ថុធាតុដើម ចំណីអាហារ ឬគ្រឿងផ្សំរបស់វា ដើម្បីបំពេញទៅតាមគោលបំណងបច្ចេកវិជ្ជាមួយក្នុងពេលធ្វើប្រព្រឹត្តិកម្ម ឬ ផលិតកម្ម ហើយដកវាចេញមកវិញនូវដំណាក់កាលក្រោយមកទៀត ប៉ុន្តែមិនអាចជៀសរួចនូវសំណល់ ឬវត្ថុកំលាយ ដែលមាននៅក្នុងផលិតផលសំរេចឡើយ ។
- **ចំណីអាហារសំរាប់គោលបំណងផ្គត់ផ្គង់ :** មានន័យថា ចំណីអាហារទាំងឡាយណា ដែលសំរាប់ប្រើប្រាស់នៅតាមភោជនីយដ្ឋាន តង់ទីន សាលារៀន មន្ទីរពេទ្យ និងនៅតាមស្ថាប័នដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា គឺសំរាប់ផ្គត់ផ្គង់ឱ្យប្រើប្រាស់ភ្លាមៗ ។

**៣_គោលការណ៍ទូទៅ :**

ផលិតផលចំណីអាហារដែលបានវេចខ្ចប់ជាមុន មិនត្រូវបានពិពណ៌នា ឬបង្ហាញនៅលើស្លាក ឬក្នុងការធ្វើស្លាកណាមួយ :

- ក្នុងលក្ខណៈមិនពិត និងនាំឱ្យមានការយល់ខុស ឬមានលក្ខណៈឆបោក ឬបង្កើតឱ្យមានការភ័ន្តច្រឡំ លើផលិតផលនោះដល់អ្នកប្រើប្រាស់

- ដោយប្រើពាក្យ រូបភាព ឬមធ្យោបាយផ្សេងៗ ចំពោះផលិតផល ទោះដោយផ្ទាល់ ឬប្រយោលក្តី ដែលអាចឱ្យមានការយល់ច្រឡំ ឬក្នុងលក្ខណៈណាមួយ ដែលបណ្តាលឱ្យអ្នកទិញ ឬអតិថិជន ស្មានថាចំណីអាហារនោះមានជាប់ទាក់ទងគ្នាជាមួយផលិតផលដទៃទៀត ។

**៤_ការចាំបាច់ក្នុងការធ្វើស្លាកសំរាប់ផលិតផលចំណីអាហារដែលបានវេចខ្ចប់ជាមុន :**

រាល់ផលិតផលចំណីអាហារដែលបានវេចខ្ចប់ជាមុន ចាំបាច់ត្រូវមានស្លាកផលិតផល ដើម្បីផ្តល់ពត៌មានច្បាស់លាស់ និងគ្រប់គ្រាន់ដល់អ្នកប្រើប្រាស់ និងភ្នាក់ងារមានសមត្ថកិច្ចគ្រប់គ្រង ។

ពត៌មានដូចខាងក្រោមនេះ ត្រូវមាននៅលើស្លាកនៃផលិតផលចំណីអាហារដែលបានវេចខ្ចប់ជាមុន និងផលិតផលកំពុងវេចខ្ចប់ :

**៤.១_ឈ្មោះចំណីអាហារ :**

ឈ្មោះផលិតផលចំណីអាហារត្រូវបង្ហាញនូវចរិតពិតរបស់ចំណីអាហារ ហើយជាធម្មតាត្រូវតែកំណត់ឱ្យបានជាក់លាក់ និង ទៅតាមប្រភេទដូចខាងក្រោម :

- ក្នុងករណីដែលមានឈ្មោះមួយ ឬឈ្មោះច្រើន ដែលត្រូវបានបង្កើតសំរាប់ចំណីអាហារក្នុងស្តង់ដារនេះ យ៉ាងហោចណាស់ឈ្មោះមួយក្នុងចំណោមឈ្មោះទាំងនោះត្រូវតែបានប្រើ
- ក្នុងករណីផ្សេងទៀត ឈ្មោះដែលបានដាក់បញ្ញត្តិដោយច្បាប់របស់រដ្ឋ ត្រូវតែបានយកមកប្រើ
- ក្នុងករណីប្រើឈ្មោះថ្មីជំនួសឈ្មោះរួម ឬឈ្មោះធម្មតាណាមួយដែលមានរួច ត្រូវប្រើពាក្យពេចន៍ ឬពិពណ៌នាឱ្យបានសមរម្យ ដែលមិនបណ្តាលឱ្យមានការយល់ខុស ឬភ័ន្តច្រឡំដល់អតិថិជន
- ឈ្មោះបង្កើតថ្មី អាចនឹងត្រូវឱ្យប្រើប្រាស់ជាឈ្មោះផលិតផល
- ឈ្មោះផលិតផលចំណីអាហារអាចបន្ថែម ជាពាក្យពេចន៍ ឃ្លាប្រយោគ ទោះជាមានការទាក់ទង ឬមានភាពដូចគ្នាទៅនឹងផលិតផលមួយទៀតក៏ដោយ គឺត្រូវជៀសវាងធ្វើឱ្យមានការភាន់ច្រឡំ ឬយល់ខុសទៅលើចរិតពិត និងលក្ខណៈរូបនៃចំណីអាហារ ប៉ុន្តែមិនកំណត់ចំពោះប្រភេទនៃការវេចខ្ចប់ រាងរៅ ហើយនឹងលក្ខខ័ណ្ឌ ឬប្រភេទនៃការកែច្នៃ ដែលបានធ្វើឡើយ
- ក្នុងករណីចាំបាច់ត្រូវបញ្ជាក់ពីស្ថានភាពរូបសាស្ត្ររបស់ផលិតផលផង ឧទាហរណ៍ : ស្ងួត ខាប់ ឆ្អែរ គ្រាប់ ឬកិនរួច ។ល។

- ឈ្មោះផលិតផលត្រូវសរសេរជាអក្សរធំក្រាស់ (Bold letter) ហើយទំហំអក្សរត្រូវតែឱ្យសមស្របទៅនឹងទំហំនៃក្រដាស ឬផ្ទាំង ដែលយកមកធ្វើជាស្លាក ។

៩.២-សញ្ញាសំគាល់ផលិតផល (ម៉ាក) :

សញ្ញាសំគាល់ផលិតផល (ម៉ាក) គឺជាតំនួសតាង ដែលមើលឃើញ សំរាប់ឱ្យអតិថិជនដឹងពីការខុសប្លែកពីគ្នានៃផលិតផលនីមួយៗ ។

ការប្រើប្រាស់សញ្ញាសំគាល់ត្រូវអនុវត្តនៅតាមបទប្បញ្ញត្តិរបស់ស្ថាប័នមានសមត្ថកិច្ច ។

៩.៣-បញ្ជីឈ្មោះគ្រឿងផ្សំ :

- ឈ្មោះគឿងផ្សំត្រូវតែបង្ហាញនៅលើស្លាក ដោយរៀបតាមលំដាប់ថយចុះគិតជាខ្នាត មាឌទម្ងន់ ឬជាភាគរយ លើកលែងតែម្ហូបអាហារដែលមានគ្រឿងផ្សំតែមួយមុខ
- ផលិតផលដែលមានគ្រឿងផ្សំពីពីរមុខឡើងទៅ ដែលគ្រឿងផ្សំមួយ ឬច្រើន លាយ ឬ ដោយគ្រឿងផ្សំជាច្រើន (ចំរុះ) នោះត្រូវធ្វើការបង្ហាញនៅក្នុងបញ្ជីឈ្មោះគ្រឿងផ្សំ ដែលត្រូវដាក់នៅក្នុងរង្វង់ក្រចក ពីក្រោយគ្រឿងផ្សំដើមនោះតាមសមាមាត្រជាបន្តបន្ទាប់
- រាល់ការបន្ថែមវីតាមីន (vitamine) ឬ សារធាតុរ៉ែ (Mineral) ត្រូវតែសរសេរបង្ហាញនៅក្នុងបញ្ជីឈ្មោះគ្រឿងផ្សំ
- ចំពោះផលិតផលដែលមានសារធាតុដូចខាងក្រោម ត្រូវតែមានការបង្ហាញនៅក្នុងបញ្ជីឈ្មោះគ្រឿងផ្សំ :
  - សូដ្យូមក្លរ (អំបិល) - (Sodium chloride/Salt)
  - សូដ្យូមនីត្រាត- (Sodium Nitrate)
  - សូដ្យូម ឬប៉ូតាស្យូមនីត្រាត- (Sodium/Potassium Nitrate)
  - ម៉ូណូសូដ្យូម គ្លុយតាម៉ាត (ប៊ីចេង) - (Monosodium Glutamate/MSG/)
  - ឈ្មោះជាក់លាក់នៃសារធាតុផ្អែមដែលគ្មានតំលៃអាហាររូបត្ថម្ភ - (Specific name for non-nutritive sweeteners)
- ទឹកដែលដាក់បន្ថែមត្រូវតែបង្ហាញនៅក្នុងបញ្ជីឈ្មោះនៃគ្រឿងផ្សំ លើកលែងតែទឹក ដែលបានក្លាយជាចំណែកនៃគ្រឿងផ្សំនួយដូចជា : ទឹកអំបិល ទឹកស៊ីរ៉ូ ឬទឹករំងាស់សាច់ដែលបានប្រើជា

គ្រឿងផ្សំចំណីអាហារ ។ ទឹក ឬគ្រឿងផ្សំដែលអាចហើរ ឬហួតនៅក្នុងពេលផលិតមិនចាំបាច់បង្ហាញនៅក្នុងបញ្ជីឈ្មោះគ្រឿងផ្សំឡើយ

- មិនចាំបាច់បង្ហាញនៅក្នុងបញ្ជីឈ្មោះគ្រឿងផ្សំឡើយនូវគ្រឿងផ្សំដូចខាងក្រោម :
  - គ្រឿងជំនួយផលិតកម្ម
  - គ្រឿងផ្សំសំរាប់ទ្រទ្រង់អង្គធាតុក្លិន រក្សាទុកឱ្យបានយូរ និងអង្គធាតុឱ្យពណ៌ដែលអាចមាននៅក្នុងផលិតផល ។

## ៤.៤-បរិមាណសុទ្ធ និង ទម្ងន់សុទ្ធនៃផលិតផល :

បរិមាណសុទ្ធនៃផលិតផលត្រូវបានបង្ហាញតាមរបៀបដូចខាងក្រោម :

ក- សំរាប់ចំណីអាហារដែលមានភាពរាវ ត្រូវបង្ហាញជាខ្នាតនៃមាឌ គិតជា : លីត្រ (l) ឬ មីល្លីលីត្រ (ml)

ខ- សំរាប់ចំណីអាហារដែលមានភាពរឹង ត្រូវបង្ហាញជាខ្នាតនៃទម្ងន់ : គីឡូក្រាម (Kg) ឬ ក្រាម (g)

គ- សំរាប់ចំណីអាហារដែលមានភាពមិនរឹងមិនទន់ ឬមានភាពខាប់អន្ទិល ត្រូវបង្ហាញជាខ្នាតនៃមាឌក៏បាន ឬជាខ្នាតនៃទម្ងន់ក៏បាន

- ត្រូវបង្ហាញជាខ្នាតចំនួន ( ប្រអប់ ដប ដុំ ឡូ) នៅលើកេស ធុង ឬកញ្ចប់ធំៗ ។
- ចំពោះបន្លែកំប៉ុង ឬផ្លែឈើកំប៉ុងដែលមានលាយទឹក ត្រូវប្រកាសតែទម្ងន់សុទ្ធនៃបន្លែ ឬផ្លែឈើទាំងនោះ ។
- **បរិមាណសុទ្ធនៃផលិតផលចំណីអាហារមួយចំនួនមិនចាំបាច់ប្រកាសឡើយ ដូចជា :**
  - **១- ស្ករគ្រាប់ដែលមានទម្ងន់ក្រោម ២០ ក្រាម**
  - **២- ដំណាប់ដែលមានទម្ងន់ក្រោម ៥០ ក្រាម**
  - ៣- រាល់ផលិតផលចំណីអាហារទាំងអស់ដែលមានបរិមាណតិចជាង ៥ ក្រាម ឬ ៥ មីល្លីលីត្រ លើកលែងតែគ្រឿងទេស និង រុក្ខជាតិផ្តល់ក្លិន ។

## ៤.៥-ឈ្មោះ និង អាស័យដ្ឋាន :

ឈ្មោះ និងអាស័យដ្ឋានរបស់ផលិតករ អ្នកវេចខ្ចប់ អ្នកកែសំរួល អ្នកចែកចាយ អ្នកនាំចូល អ្នកនាំចេញផលិតផលចំណីអាហារត្រូវតែប្រកាសនៅលើស្លាកនៃផលិតផល ។

**៥.៦-ប្រភពផលិតផល :**

- ត្រូវតែមានការប្រកាសជាពិសេស អំពីប្រភពដើម ឬ ប្រទេសដើមនៃផលិតផលចំណីអាហារ ដើម្បីជៀសវាងការយល់ច្រឡំ ឬ បំភាន់ដល់អ្នកប្រើប្រាស់ពីប្រភព ឬ កន្លែងដើមនៃផលិតផល ។
- ចំពោះចំណីអាហារដែលយកមកផលិតនៅប្រទេសទី ២ ហើយដែលត្រូវផ្លាស់ប្តូរចរិតលក្ខណៈរបស់វា ប្រទេសនោះត្រូវបានចាត់ទុកថាជាប្រទេសដើម ឬ ប្រភពផលិតផល ដែលត្រូវបង្ហាញនៅលើស្លាកផលិតផល ។

**៥.៧-លេខឡូត៍នៃផលិតផល :**

រាល់ផលិតផលចំណីអាហារ ត្រូវតែមានការបង្ហាញជាអចិន្ត្រៃយ៍នៅលើស្លាកផលិតផល ឬ សំបកវេចខ្ចប់នូវលេខកូដច្បាស់លាស់ សំរាប់សំគាល់រោងចក្រដែលផលិត និងឡូត៍ផលិតផល ដើម្បីឱ្យមានការទទួលខុសត្រូវរបស់អ្នកផលិតនៅក្នុងករណីណាមួយ និង ដើម្បីងាយស្រួលដល់ការតាមដានរបស់ភ្នាក់ងារមានសមត្ថកិច្ច ។

**៥.៨-ការកំណត់កាលបរិច្ឆេទ និង ការណែនាំក្នុងការរក្សាទុកផលិតផល :**

ត្រូវបង្ហាញកាលបរិច្ឆេទនៃផលិតផលដូចតទៅ :

ក- ត្រូវបញ្ជាក់ថាផលិតផលចំណីអាហារនោះអាចរក្សាបាននូវ ក្លិន ពណ៌ រសជាតិ គុណភាព សុវត្ថិភាព នៅក្នុងកំឡុងពេលមួយជាកំណត់ :

- **ថ្ងៃ និង ខែ ចំពោះផលិតផលណា ដែលមានរយៈពេលអប្បបរមា នៃការរក្សាទុកមិនលើសពី ០៣ខែ**
- **ខែ និង ឆ្នាំ ចំពោះផលិតផលណា ដែលមានរយៈពេលអប្បបរមា នៃការរក្សាទុក លើសពី ០៣ខែ**

ខ- កាលបរិច្ឆេទត្រូវបានបង្ហាញដោយពាក្យ :

- ថ្ងៃផលិត : ....................( *កាលបរិច្ឆេទនៃការផលិត*)
- ថ្ងៃវេចខ្ចប់ : ....................( *កាលបរិច្ឆេទនៃការវេចខ្ចប់*)
- ថ្ងៃផុតកំណត់ : ....................( *កាលបរិច្ឆេទផុតកំណត់*)

- ល្អបំផុតបើប្រើមុនថ្ងៃ : ..........ឬមុនដំណាច់ខែ..........( *កាលបរិច្ឆេទនៃរយៈកាលអប្បបរមា* )

គ- ថ្ងៃ ខែ ឆ្នាំ ត្រូវបង្ហាញជាលេខ លើកលែងតែខែអាចសរសេរជាអក្សរ ដែលមិនបណ្តាលឱ្យអ្នកប្រើប្រាស់មានការច្រឡំ ។

ឃ- អាចអនុគ្រោះមិនបាច់បង្ហាញការកំណត់កាលបរិច្ឆេទទៅលើផលិតផលមួយចំនួនដូចជា :

១- បន្លែស្រស់ មើម ផ្លែឈើស្រស់ ដែលស្ថិតនៅក្នុងស្ថានភាពដើមមិនទាន់កែច្នៃ

២- ស្រាគ្រប់ប្រភេទ

៣- ភេសជ្ជៈ ដែលមានអត្រាជាតិអាល់កុលខ្ពស់ជាង ១០% គិតជាមាឌ

៤- ទឹកខ្មេះ អំបិលសម្ងួរ ស្ករស ការ៉េមក្លាសេ ស្ករគ្រាប់ ស្ករកៅស៊ូ

៥- ផលិតផលប្រភេទនំប៉័ង ដែលជាធម្មតាទុកសំរាប់តែប្រើប្រាស់ក្នុងកំឡុងពេល ២៤ម៉ោង ។

ង- ប្រសិនបើរយៈពេលនៃការកំណត់កាលបរិច្ឆេទផ្អែកទៅលើលក្ខខ័ណ្ឌពិសេសណាមួយនោះត្រូវសរសេរបញ្ជាក់បន្ថែម អំពីលក្ខខ័ណ្ឌពិសេសទាំងនោះនៅលើស្លាកផលិតផល ។

**៤.៩-វិធីប្រើ :**

អ្នកផលិតអាចមិនបង្ហាញពីវិធីប្រើក៏បាន ប៉ុន្តែក្នុងករណីចាំបាច់ត្រូវបង្ហាញពីវិធីប្រើរួមទាំងលក្ខខ័ណ្ឌ ឬកន្លែងណាដែលអាចប្រើប្រាស់បានដោយបញ្ជាក់នៅលើស្លាកផលិតផល ។ ចំណុចសំខាន់ គឺត្រូវបញ្ជាក់នូវរបៀបប្រើប្រាស់ចំណីអាហារនោះឱ្យបានត្រឹមត្រូវ ។

**៥-អត្ថបទចាំបាច់ដែលត្រូវបញ្ជាក់បន្ថែម :**

**៥.១-ការធ្វើស្លាកអំពីបរិមាណនៃគ្រឿងផ្សំ**

នៅពេលដែលការធ្វើស្លាកលើចំណីអាហារមួយ មានការសង្កត់បញ្ជាក់ជាពិសេសអំពីវត្តមាននៃគ្រឿងផ្សំមួយ ឬ ច្រើនដែលមានតំលៃ និងដែលមានលក្ខណៈប្លែក ឬនៅពេលដែលការអធិប្បាយអំពីចំណីអាហារមានប្រសិទ្ធភាពដូចគ្នា ភាគរយដំបូងនៃគ្រឿងផ្សំ (ម៉ាស់/ម៉ាស់) នៅពេលផលិតត្រូវតែមានការបង្ហាញ ។

ក៏ដូចគ្នានេះដែរ នៅពេលដែលការធ្វើស្លាកនៃចំណីអាហារមួយមានការសង្កត់បញ្ជាក់ជាពិសេសអំពីបរិមាណតិចនៃគ្រឿងផ្សំមួយ ឬច្រើន ភាគរយនៃគ្រឿងផ្សំ (ម៉ាស់/ម៉ាស់) នៅក្នុងផលិតផលសំរេចត្រូវតែបានប្រកាស ។

៥.២-ចំណីអាហារដែលបានបាញ់កាំរស្មី :

- នៅលើស្លាកផលិតផលចំណីអាហារដែលបានបាញ់កាំរស្មី ត្រូវសរសេរអះអាងដោយបង្ហាញពីការបាញ់កាំរស្មីទៅលើចំណីអាហារនោះ ។ និមិត្តសញ្ញាអន្តរជាតិនៃការប្រើកាំរស្មីទៅលើចំណីអាហារ មានរូបរាងដូចខាងក្រោម :

**និមិត្តសញ្ញាអន្តរជាតិនៃការប្រើកាំរស្មីទៅលើចំណីអាហារ**

- នៅពេលដែលផលិតផលត្រូវបានប្រើកាំរស្មី ហើយត្រូវបានប្រើជាគ្រឿងផ្សំយកទៅដាក់ក្នុងចំណីអាហារផ្សេងទៀតនោះ ត្រូវតែបញ្ជាក់នៅក្នុងបញ្ជីរាយនាមរបស់គ្រឿងផ្សំនោះដែរ ។
- កាលណាផលិតផលជាគ្រឿងផ្សំទោលមួយ ដែលបានផលិតពីវត្ថុធាតុដើម ដែលបានទទួលការបាញ់កាំរស្មី ស្លាកផលិតផលត្រូវមានការអះអាងបង្ហាញពីការប្រើកាំរស្មី ។

## ៦-ការលើកលែងពីការតំរូវជាចាំបាច់ក្នុងការធ្វើស្លាក :

ចំពោះផលិតផលជាគ្រឿងទេស និងស្លឹកជី ខ្ចីម ដែលសំបកវេចខ្ចប់មានទំហំតូចជាង ១០សមអាចត្រូវបានលើកលែងដោយមិនចាំបាច់អនុវត្តតាមការតំរូវក្នុងកថាខ័ណ្ឌ ៤.២ និង ៤.៦ ទៅ ៤.៨ ឡើយ ។

### ៧.ការធ្វើស្លាកផលិតផលតាមការយល់ឃើញ :

ពតិមានណា ឬការប្រើរូបភាពណាដែលមានសារៈសំខាន់ អាចត្រូវបានអនុញ្ញាតឱ្យបង្ហាញនៅលើស្លាកផលិតផលបាន លុះណាតែមិនប៉ះពាល់ដល់ការតំរូវជាចាំបាច់នៃស្តង់ដារនេះ និង ដល់អ្វីដែលទាក់ទងទៅនឹងការអំអាង និងការបំភាន់នៅក្នុងចំណុច ៣ ដែលស្តីពីគោលការណ៍ទូទៅ ។

ចំពោះទំរង់អក្សរដែលបានប្រើប្រាស់ គឺត្រូវងាយអាន ងាយយល់ មិនត្រូវឱ្យមានការយល់ច្រឡំ ឬបំភាន់តាមវិធីណាមួយឡើយ ។

### ៨.ការបង្ហាញពីជំនើចចាំបាច់ :

#### ៨.១.លក្ខណៈទូទៅ :

ការអះអាងដែលបានតំរូវឱ្យមាននៅលើស្លាកផលិតផលត្រូវធ្វើឱ្យបានត្រឹមត្រូវតាមស្តង់ដារ ។ ការអះអាងនោះត្រូវលេចចេញច្បាស់ៗ ដែលលុបមិនជ្រះ និងអានបានដោយអ្នកប្រើប្រាស់ក្នុងលក្ខខ័ណ្ឌធម្មតានៃការលក់ដូរ និងការប្រើប្រាស់ ។

ផលិតផលណាដែលសំបកវេចខ្ចប់មានការរុំ ឬខ្ចប់បន្ថែមពីក្រៅ ហើយបាំងស្លាកផលិតផលខាងក្នុងគ្រឿងរុំ ឬខ្ចប់បន្ថែមពីក្រៅនោះ ត្រូវផ្តល់ពតិមានចាំបាច់ ឬ ប្រើសញ្ញា ដែលអាចមើលឃើញ និងអានបានពីលើគ្រឿងរុំ ឬ ខ្ចប់បន្ថែមពីក្រៅនោះ ។ ខ្លឹមសារនៃការផ្តល់ពតិមានចាំបាច់ទាំងនោះ មិនត្រូវឱ្យផ្ទុយទៅនឹងខ្លឹមសារនៃការផ្តល់ពតិមានរបស់ស្លាកខាងក្នុងឡើយ ។

ឈ្មោះ និងបរិមាណសុទ្ធរបស់ចំណីអាហារត្រូវលេចចេញយ៉ាងច្បាស់លាស់ត្រង់កន្លែងណាមួយ និងក្នុងផ្នែកតែមួយដែលអាចមើលឃើញ ។

#### ៨.២.ភាសា :

ចំពោះផលិតផលទាំងអស់ដែលផលិតក្នុងស្រុកសំរាប់ធ្វើចរាចរក្នុងប្រទេស នៅលើស្លាកចាំបាច់ត្រូវសរសេរជាភាសាខ្មែរ ។ អាចអនុគ្រោះឱ្យសរសេរបន្ថែមជាភាសាអន្តរជាតិបាន ( បារាំង អង់គ្លេស ចិន ។ល ។) តែទំហំអក្សរត្រូវតែតូចជាងអក្សរខ្មែរ ។

ចំពោះផលិតផលនាំចូលត្រូវសរសេរ ឬ បិទបន្ថែមអក្សរខ្មែរដែលអាចទទួលបានដោយអ្នកប្រើប្រាស់ ។ ពតិមានចាំបាច់ ដែលត្រូវសរសេរជាភាសាខ្មែរត្រូវមានលក្ខណៈពេញលេញ និងត្រឹមត្រូវតាមស្លាកដើម ។

**៨.៣-ការហាមឃាត់នៅលើស្លាកផលិតផល :**

- មិនត្រូវសរសេរនូវអ្វី ដែលបណ្ដាលឱ្យអ្នកប្រើប្រាស់យល់ច្រឡំពីផលិតផលនោះ
- មិនត្រូវបង្ហាញធ្វើឱ្យមានការយល់ច្រឡំដល់អ្នកប្រើប្រាស់នូវបរិមាណ និង ទំងន់សុទ្ធនៃផលិតផល
- មិនត្រូវបញ្ជាក់គុណភាពផលិតផលថាល្អលេខ ១ មុនពេលដែលស្ថាប័នមានសមត្ថកិច្ចចេញវិញ្ញាបនប័ត្របញ្ជាក់ទទួលស្គាល់
- មិនត្រូវសរសេរកែប្រែចំណីអាហារឱ្យទៅជាថ្នាំពេទ្យសំរាប់ព្យាបាលជំងឺ លើកលែងតែទឹកធម្មជាតិ ។

***

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០

## ប្រកាសលេខ ៩៩២ ឧរថក ឧ.ប្រក

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

****

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្ដេច នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ២៩៤៨/០០ គ.វ.ក ចុះថ្ងៃទី ១៣-១០-២០០០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ១២៣៣ ប.ស្ថ សណ ចុះថ្ងៃទី ០៧-១១-២០០០ របស់ក្រសួងបរិស្ថាន
- បានឃើញលិខិតលេខ ២២៥៣ សក.នល ចុះថ្ងៃទី ២១-០៨-១៩៩៥ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន

- យោងពាក្យស្នើរបស់ក្រុមហ៊ុន ហង់ ហ្វ៊ុង ស្ស៊ីង ( ខេមបូឌា ) ហ្គាមេន ហ្វេកធើរី ចុះថ្ងៃទី ០៨-១១-២០០០

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន ហង់ ហ្វ៊ុង ស្ស៊ីង ( ខេមបូឌា ) ហ្គាមេន ហ្វេកធើរី ( HANG FUNG SHING ( CAMBODIA ) GARMENT FACTORY CO., LTD ) តំណាងដោយលោក CHEUNG CHUN KEUNG សញ្ជាតិ ចិន ភេទ ប្រុស អាយុ ៦៤ ឆ្នាំ កាន់លិខិតឆ្លងដែនលេខ H 90019941 ចុះថ្ងៃទី 29-10-1997 បង្កើតរោងចក្រកាត់ដេរ សំលៀកបំពាក់នាំចេញ ដែលមានឈ្មោះ " ហង់ ហ្វ៊ុង ស្ស៊ីង ( ខេមបូឌា ) " មានទីតាំងស្ថិតនៅអតីតរោងចក្រឡឥដ្ឋទី១ ដីឡូត៍លេខ ១២២៣ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៣ :** រោងចក្រនេះត្រូវបានអនុញ្ញាតអោយ " កាត់-ដេរ សំលៀកបំពាក់ " ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ ថាមពល ។

**ប្រការ ៤ :** ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ ៥ :** រាល់ការ[illegible]ចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវស៊ីវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៦ :** ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពអោយបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់ បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

**ប្រការ ៧ :** ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៨ :** អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន ហង់ ហ្វ៊ុង ស្ស៊ីង ( ខេមបូឌា ) ហ្គាមេន ហ្វេកធើរី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងខ្លួន ។

**ប្រការ ៩ :** ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ស៊ុយ សែម**

★★★

# ធនាគារជាតិនៃកម្ពុជា

## ប្រកាស លេខ ៥០០-១៧០ ប្រក

## ស្តីពី

## សភាផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល

### ទេសាភិបាល ធនាគារជាតិ នៃកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃធនាគាជាតិ នៃកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៣៩៨/៩៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិ នៃកម្ពុជា

-យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

### សំរេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**ប្រការ ១ :**

ដាក់ចេញនូវបទបញ្ជាសភាផាត់ទាត់មូលប្បទានបត្រ ចារឹកជាប្រាក់រៀល ដែលកំណត់អំពីលក្ខខ័ណ្ឌទាំងឡាយ សំរាប់អនុវត្តចំពោះការងារទូទាត់ប្រចាំថ្ងៃ នូវមូលប្បទានបត្រ ក្នុងចំណោមសមាជិកសភាផាត់ទាត់លើគណនីប្រាក់បញ្ញើរបស់ខ្លួន ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា តាមប្រការជាបន្តបន្ទាប់ដូចខាងក្រោម ។

**ប្រការ ២ : អំពីសមាជិកភាព**

១- ធនាគារដែលមានបំណងចូលជាសមាជិកសភាផាត់ទាត់ ត្រូវដាក់ពាក្យ ស្នើសុំតាមគំរូក្នុងឧបសម្ព័ន្ធ ១ ។

ប្រសិនបើមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ធនាគារសាមីនឹងត្រូវបានធនាគារជាតិនៃកម្ពុជាបញ្ចូលជាសមាជិក នៅថ្ងៃធ្វើការទីមួយនៃខែបន្ទាប់ ។ សមាជិកនៃសភាផាត់ទាត់ត្រូវបានរាយឈ្មោះក្នុងបញ្ជីរាយនាមដូចមានក្នុងឧបសម្ព័ន្ធ ២ ។

២- ធនាគារដែលមិនមែនជាសមាជិក ត្រូវបានអនុញ្ញាតអោយមានតំណាងក្នុងសភាផាត់ទាត់ជំនួសខ្លួន ដោយធនាគារជាសមាជិក ចំពោះសំណូមពរផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ។ ការ

សុំអោយមានតំណាងនេះ ត្រូវបានយល់ព្រមជាលាយល័ក្ខណ៍អក្សរ ដោយធនាគារជាតិនៃកម្ពុជា ជាមុន ។

ប្រការ ៣ : លក្ខណៈសម្បត្តិជាសមាជិក

- ធនាគារដែលធនាគារជាតិនៃកម្ពុជចេញអាជ្ញាប័ណ្ណអោយប្រកបអាជីវកម្ម អាចសុំចូលជាសមាជិក ។

បែបបទនៃការស្នើសុំរួមមាន ៖

- ពាក្យសុំចូលជាសមាជិកដែលមានចុះហត្ថលេខានាយកធនាគារ ឬ អ្នកដែលទទួលសិទ្ធិប្រទាន
- ច្បាប់ថតចំលងនៃអាជ្ញាប័ណ្ណដែលចេញដោយធនាគារជាតិនៃកម្ពុជា
- លិខិតឧទ្ទេសនាម និង សំរូបហត្ថលេខា ។

លើសពីនេះទៀត ធនាគារជាសមាជិកត្រូវ ៖

- មានគណនីចរន្តជាប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា
- បង់សោហ៊ុយសេវា តាមការកំណត់របស់ ធនាគារជាតិនៃកម្ពុជា ។

២- ធនាគារជាតិ ជាសមាជិកត្រូវមានទីស្នាក់ការធ្វើប្រតិបត្តិការនៅភ្នំពេញ ។

ប្រការ ៤ : ការបាត់បង់សមាជិកភាព

១- ធនាគារដែលត្រូវមានធនាគារជាតិនៃកម្ពុជាដកហូតអាជ្ញាប័ណ្ណ ពុំអាចចូលរួមក្នុងសភាផាត់ទាត់បានទេ ។

២- ធនាគារអាចដកខ្លួនចេញដោយស្ម័គ្រចិត្តពីសភាផាត់ទាត់ អោយតែធនាគារនោះបានធ្វើការសំរបសំរួលត្រឹមត្រូវ ជាមួយនឹងធនាគារមួយទៀតជាសមាជិក អោយកាន់កាប់មូលប្បទានប័ត្រ ដើម្បីផាត់ទាត់ជំនួសខ្លួន ដោយមានការយល់ព្រមជាលាយល័ក្ខណ៍អក្សរ ពីធនាគារជាតិនៃកម្ពុជា ជាមុន ។

ប្រការ ៥ : ធនាគារទូទាត់

ធនាគារជាតិនៃកម្ពុជា ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ប្រចាំថ្ងៃ អំពីទឹកប្រាក់សរុបនៃមូលប្បទានប័ត្រ ដែលសភាផាត់ទាត់បានបញ្ចូលទៅ និងទទួលយក និងគណនាទឹកប្រាក់សុទ្ធ ដែលត្រូវចុះឥណពន្ធ ឬ ចុះឥណទានគណនីចរន្តរបស់ធនាគារសមាជិកនីមួយៗ ។

ប្រការ ៦ : អំពីការគ្រប់គ្រង

១-ធនាគារជាតិនៃកម្ពុជា ត្រូវជ្រើសតាំងប្រធានសភាផាត់ទាត់ ដែលទទួលបន្ទុកប្រតិបត្តិការសភាផាត់ទាត់ ។

ប្រធានអាចប្រគល់ភារកិច្ចត្រួតពិនិត្យ និងតាមដានមុខងារប្រចាំថ្ងៃទៅអោយអ្នកដឹកនាំផាត់ទាត់ ។

ប្រធានសភាផាត់ទាត់ និងអ្នកដឹលនាំផាត់ទាត់ត្រូវតែជាមន្ត្រីធនាគារជាតិនៃកម្ពុជា ។

២-ករណីកើតមានវិវាទរវាងតំណាងរបស់ធនាគារសមាជិក ក្នុងពេលប្រគល់ ឬទទួលការទូទាត់ ឬពាក់ព័ន្ធជាមួយទឹកប្រាក់ត្រូវទូទាត់ ការសំរេចរបស់អ្នកដឹកនាំផាត់ទាត់ អាចត្រូវទទួលយកជាបណ្តោះអាសន្ន ដោយមានទិដ្ឋាការរបស់ប្រធានសភាផាត់ទាត់ ។ ក្នុងករណីនៅបន្តមានការជំទាស់ក្រោយការសំរេចការដោះស្រាយ ត្រូវធ្វើដោយផ្ទាល់ រវាងធនាគារដែលពាក់ព័ន្ធ ។

ប្រការ ៧ : គណៈកម្មាធិការប្រតិបត្តិការ :

១-ការងារសភាផាត់ទាត់ ត្រូវបន្ថែមដោយគណៈកម្មាធិការប្រតិបត្តិការ ដែលរួមមានតំណាងមួយរូប របស់ធនាគារសមាជិកនិមួយៗ និងដឹកនាំដោយប្រធានមួយរូប ជ្រើសរើសដោយសមាជិក ។ ប្រធានត្រូវបំរើការរយៈពេលមួយឆ្នាំ ។ អ្នកដឹកនាំបន្ទាប់នឹងត្រូវតែងតាំង និងបោះឆ្នោតជ្រើសរើសដោយសមាជិកសភាផាត់ទាត់ ។

២-គណៈកម្មាធិការប្រតិបត្តិការ មាននមុខងារដូចតទៅ ៖

-ពិគ្រោះផ្តល់យោបល់ ដើម្បីលើកកំពស់គុណភាពប្រតិបត្តិការផាត់ទាត់

-ពង្រឹងសណ្តាប់ធ្នាប់ និងវិន័យរបស់តំណាងសមាជិក

-អនុវត្តអោយបានប្រសើរឡើងនូវភារកិច្ចដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ឬដោយគណៈកម្មាធិការ ។

៣-គណៈកម្មាធិការប្រតិបត្តិការត្រូវជួបប្រជុំយ៉ាងហោចណាស់៤ដង ក្នុងមួយឆ្នាំ ។ ការប្រជុំបន្ថែមអាចធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធាន ឬនៅពេលមានសំណូមពរជាលាយល័ក្ខណ៍អក្សររបស់សមាជិកពីររូបយ៉ាងតិច ដោយមានបញ្ជាក់ច្បាស់លាស់នូវកម្មវត្ថុដែលត្រូវពិភាក្សា ។

ប្រការ ៨ : ការកែប្រែបទបញ្ជា

ខ្លឹមសារនិងល័ក្ខខ័ណ្ឌនៃបទបញ្ជាផាត់ទាត់អាចនឹងត្រូវកែប្រែពីពេលមួយទៅពេលមួយ តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ឬដោយមានការព្រមព្រៀងជាមួយគណៈកម្មាធិការប្រតិបត្តិការ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាអាចពង្រីកប្រតិបត្តិការ ផាត់ទាត់ទៅខេត្ត-ក្រុងដទៃទូទាំងប្រទេស បន្ថែមសេវាផ្សេងៗទៀតបើយល់ថាចាំបាច់ ដើម្បីធ្វើអោយប្រសើរឡើងនូវប្រព័ន្ធទូទាត់ ។

## ជំពូកទី ២
## និយមន័យ នៃពាក្យបច្ចេកទេស

**ប្រការ ៩ :** ពាក្យបច្ចេកទេសដែលបានប្រើក្នុងបទបញ្ញាមាននិយមន័យដូចតទៅនេះ ៖

១-ថ្ងៃធ្វើការ (Business Day) គឺពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ឬថ្ងៃបន្ថែមណាមួយដែលធនាគារជាតិ នៃកម្ពុជា បានកំណត់បើកធ្វើការ ។ ថ្ងៃធ្វើការមិនរាប់បញ្ចូលថ្ងៃឈប់សំរាកជាសាធារណៈទេ ។

២-សភាផាត់ទាត់ (Clearing House) គឺជាមណ្ឌលសំរួលការផាត់ទាត់ ដែលធ្វើឡើងដោយធនាគារជាតិ នៃកម្ពុជា នៅទីស្នាក់ការកណ្តាលរបស់ខ្លួននៅភ្នំពេញ ។

៣-ឧបករណ៍ទូទាត់ (Payment or item) គឺជាមូលប្បទានប័ត្រចេញផ្សាយលើគណនីចរន្តរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។ មូលប្បទានប័ត្រ គឺជាបញ្ជារបស់ម្ចាស់គណនីនៅធនាគារមួយ អោយទូទាត់ប្រាក់ពីគណនីនោះទៅអោយអត្ថគាហក ។

៤-ឧបករណ៍បង្វិលវិញ ឬ មិនទូទាត់ (Returmed or unpaid item) គឺជាមូលប្បទានប័ត្រដែលមិនអាចទូទាត់ដោយសមាជិកទទួលដោយមូលហេតុទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ ៣ ។

៥-ឧបករណ៍ដែលអាចទទួលយកបាន (Eligible items) នៅសភាផាត់ទាត់រួមមាន ៖

ក-មូលប្បទានប័ត្ររបស់ធនាគារ ដែលបានចេញផ្សាយដោយគតិយជន ត្រូវសងទៅអោយគតិយជននៅទីស្នាក់ការធនាគារប្រតិស្រុតនៅភ្នំពេញ ។

ខ- មូលប្បទានប័ត្រចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា

គ-ឧបករណ៍ឥណពន្ធខ្លះទៀត ដែលធនាគារជាតិនៃកម្ពុជា កំណត់ថាអាចទទួលយកបាន ។ មូលប្បទានប័ត្រត្រូវបានចេញផ្សាយតាមទ្រង់ទ្រាយអនុញ្ញាត ដែលបានផ្តល់ដោយ គមានការមានលំនាំស្តង់ដារ ដូចដែលបានដាក់ចេញដោយធនាគាជាតិនៃកម្ពុជា ។ មូលប្បទានប័ត្រអាចត្រូវចេញផ្សាយជាភាសាខ្មែរ អង់គ្លេស ឬបារាំង ។

៦-សមាជិក (Participant ) គឺជាធនាគារដែលយល់ព្រមចូលរួមក្នុងសភាផាត់ទាត់ ក្រោមខ្លឹមសារ និងល័ក្ខខ័ណ្ឌនៃបទបញ្ញានេះ ។

៧-ការចូលរួម (Participation ) គឺជាវត្តមានក្នុងគ្រាផាត់ទាត់ប្រចាំថ្ងៃរបស់សភាផាត់ទាត់ ។ សមាជិកត្រូវចូលរួមរាល់គ្រាផាត់ទាត់ទោះបីមានឬគ្មានមូលប្បទានប័ត្រ ដើម្បីបញ្ជូនទៅសមាជិកដទៃក្តី ។

៨-សមាជិកទទួល ( Receiving Participant ) គឺជាសមាជិក ដែលទទួលការទូទាត់ជាមូលប្បទានប័ត្រ តាមរយៈសភាផាត់ទាត់ ។ សមាជិកនេះក៏អាចហៅផងដែរថាជាធនាគារចំណាយសង (Paying Bank) ។

៩-សមាជិកប្រគល់ ( Sending Participant ) គឺជាសមាជិកដែលប្រគល់មូលប្បទានប័ត្រសំរាប់ការ ទូទាត់តាមរយៈសភាផាត់ទាត់ ។

១០-កិច្ចបញ្ជីការ ( Books ) គឺជាការកត់ត្រាគណនេយ្យលើគណនី អតិថិជន ដែលបើកនៅធនាគារ និងគណនីចរន្តរបស់ធនាគារ ដែលបើកនៅធនាគារជាតិនៃកម្ពុជា ។

១១-ការកត់ត្រា ( Posting ) គឺជាការចុះឥណពន្ធគណនីអតិថិជន សំរាប់មូលប្បទានប័ត្រ ដោយធនាគារទទួល ។

១២-ការទូទាត់ ( Settlement ) គឺជាលេខនាំនៃឥណពន្ធសុទ្ធ ឬ ឥណទានសុទ្ធក្នុងគណនីផាត់ទាត់ របស់ធនាគារ ជាសមាជិកសំរាប់ការផាត់ទាត់ប្រចាំថ្ងៃ ។ ការទូទាត់ទាំងអស់ត្រូវបានធ្វើជាបណ្តោះអាសន្ន និង អាចត្រូវដកហូតមកវិញចំពោះការទូទាត់ណា ដែលត្រូវបដិសេធដោយសមាជិកទទួល ហើយបង្វិលវិញដូចដែលបានចែងក្នុងបទបញ្ញា ។

១៣-លេខអត្តសញ្ញាណ ( Routing number ) គឺជាលេខសំគាល់របស់សមាជិក ដូចដែលបានរាយក្នុងសៀវភៅរាយឈ្មោះរបស់ធនាគារដែលកាន់កាប់ដោយ ធនាគារជាតិនៃកម្ពុជា ។ លេខអត្តសញ្ញាណ ត្រូវបានប្រើដើម្បីជ្រើសរើសនូវការទូទាត់ក្នុងចំណោមសមាជិកនៃសភាផាត់ទាត់ និងត្រូវបោះពុម្ពត្រង់កន្លែងសរមេគ្រាលើមូលប្បទានប័ត្រ ដោយអនុលោមតាមគំរូរបស់ធនាគារជាតិ នៃកម្ពុជា ។

១៤-គ្រាផាត់ទាត់ ( Session ) គឺជាការប្រជុំរបស់សមាជិកសភាផាត់ទាត់ ដើម្បីប្តូរមូលប្បទានប័ត្រទៅវិញ ទៅមក ។ គ្រាផាត់ទាត់សំខាន់នឹងប្រព្រឹត្តទៅនៅម៉ោង ១០:០០ ព្រឹក ហើយគ្រាផាត់ទាត់បន្ទាប់បន្សំសំរាប់បង្វិលវិញនូវមូលប្បទានប័ត្រប្រព្រឹត្តទៅនៅម៉ោង ៣:០០ រសៀល ។ ប៉ុន្តែប្រធានអាចសំរេចយកគ្រាផាត់ទាត់បន្ថែមក្នុងថ្ងៃណាមួយ ប្រសិនបើយល់ថាចាំបាច់ ។

១៥-គណនីផាត់ទាត់ ( Clearing Account ) គឺជាគណនីដែលបើកដោយសមាជិកនីមួយៗនៅធនាគារជាតិនៃកម្ពុជា សំរាប់ទូទាត់កាតព្វកិច្ចប្រចាំថ្ងៃរបស់ខ្លួននៅសភាផាត់ទាត់ ។ គណនីនេះត្រូវបានប្រើសំរាប់ទូទាត់កាតព្វកិច្ចរបស់សភាផាត់ទាត់ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវរបស់ធនាគារប្រគល់

**ប្រការ ១០ :**

ធនាគារទាំងឡាយត្រូវប្រើប្រាស់សភាផាត់ទាត់ ដើម្បីប្រគល់មូលប្បទានប័ត្រទៅអោយសមាជិកដទៃ ។ ការប្រគល់មូលប្បទានប័ត្រទ្វេភាគី ក្រៅពីគ្រាប្រជុំនៃសភាផាត់ទាត់ ត្រូវបានអនុញ្ញាតតែលើការព្រមព្រៀងទៅវិញទៅមក ពិសេសរវាងសមាជិកសភាផាត់ទាត់ផ្ទាល់ ។

**ប្រការ ១១ :** សមាជិកប្រគល់ត្រូវ ៖

១-អនុញ្ញាតនិងកំណត់អត្តសញ្ញាណនៃការប្រគល់

មូលប្បទានប័ត្រទាំងអស់ត្រូវបោះត្រារបស់សមាជិកប្រគល់ និងកាលបរិច្ឆេទនៃការបញ្ជូននៅខាងខ្នងនៃមូលប្បទានប័ត្រនីមួយៗ ។

២-រៀបចំការប្រគល់អោយបានត្រឹមត្រូវ

សមាជិកប្រគល់ម្នាក់ៗ ត្រូវរៀបចំតារាងនៃមូលប្បទានប័ត្រជាពីរច្បាប់គំរូ PPCOO1 បង្ហាញនូវទឹកប្រាក់នៃមូលប្បទានប័ត្រនីមួយៗ និងតំលៃសរុបនៃមូលប្បទានប័ត្រដែលត្រូវដកប្រាក់ (Draw on) ពីសមាជិកដទៃ ។ ឧទាហរណ៍នៃគំរូទាំងអស់បង្ហាញក្នុងឧបសម្ព័ន្ធ ៥ ។ តារាងគំរូ PPCOO1 ត្រូវបានរៀបចំសំរាប់សមាជិក នីមួយៗ ដោយបង្ហាញនូវ ៖

ក-ទឹកប្រាក់សរុប និង ចំនួននៃមូលប្បទានប័ត្រចេញផ្សាយនៅបណ្តាទីស្នាក់ការភ្នំពេញដែលបានបង្ហាញដល់សមាជិកទាំងនោះ និង

ខ-មូលប្បទានប័ត្រមិនទូទាត់ បង្វិលវិញ និងមិនអាចទទួលយកបាន ។

សមាជិកប្រគល់ម្នាក់ៗ ត្រូវប្រគល់ថាសកុំព្យូទ័រមួយដែលមានផ្ទុកនូវតារាងនៃគំរូ PPCOO1 ។

៣-ចូលរួមទៀងទាត់ ក្នុងគ្រាផាត់ទាត់

មូលប្បទានប័ត្រត្រូវបានយកទៅសភាផាត់ទាត់នៅម៉ោងកំណត់ ឬមុនម៉ោងកំណត់នៃថ្ងៃធ្វើការនីមួយៗ

សមាជិកដែលតំណាងរបស់ខ្លួនមកដល់យឺតក្រោយពេលកំណត់គ្រាផាត់ទាត់លើសពី៥នាទី អាចត្រូវផ្អាកមិនអោយចូលរួមគ្រាផាត់ទាត់នោះ ដោយអ្នកដឹកនាំផាត់ទាត់ ។ សមាជិកដែលត្រូវផ្អាកមិនអោយចូលរួមក្នុងគ្រាផាត់ទាត់ មិនអាចប្រគល់មូលប្បទានប័ត្រទៅសមាជិកដទៃឡើយ ។ ប៉ុន្តែសមាជិកនោះត្រូវទទួលយក ហើយគណនីរបស់ខ្លួនត្រូវបានចុះឥណពន្ធនូវមូលប្បទានប័ត្រដែលសមាជិកដទៃប្រគល់អោយខ្លួន ។

៤-អនុញ្ញាតអោយចុះឥណពន្ធគណនីចំពោះមូលប្បទានប័ត្របង្វិលវិញ

ក្នុងករណីមានការបង្វិលវិញនៃមូលប្បទានប័ត្រដែលបានបដិសេធដោយសមាជិកទទួល សមាជិកប្រគល់ ត្រូវអនុញ្ញាតអោយធនាគារជាតិនៃកម្ពុជា ចុះឥណពន្ធគណនីចរន្តរបស់ខ្លួនវិញ។

៥-រក្សាទុកនូវការកត់ត្រា

សមាជិកប្រគល់ត្រូវរក្សាទុកនូវការកត់ត្រាពាក់ព័ន្ធទាំងអស់ដែលចាំបាច់ ដើម្បីបង្កើតឡើងវិញនូវការផ្ញើ ឬការទូទាត់ដាច់ពីគ្នា សំរាប់រយៈពេលមួយឆ្នាំ ក្រោយកាលបរិច្ឆេទបង្ហាញដំបូង ។ ប៉ុន្តែ

នេះមិនបញ្ជាក់នូវកាតព្វកិច្ចដើម្បីស្រាវជ្រាវ ផ្តល់នូវការទាក់ទងអតិថិជន ឬដោះស្រាយនូវការកែតំរូវការទូទាត់យឺតជាងរយៈពេលនេះទេ ។

## ជំពូកទី ៤

## ការទទួលខុសត្រូវរបស់ធនាគារទទួល

ប្រការ ១២ :

ធនាគារទទួល ត្រូវទទួលយកមូលប្បទានប័ត្រដែលបានប្រគល់អោយខ្លួននៅសភាផាត់ទាត់ រៀងរាល់ថ្ងៃ ដោយរួមបញ្ចូលទាំងមូលប្បទានប័ត្រមិនទូទាត់ដូចមានចែងក្នុងប្រការ១១ ។ មូលប្បទានប័ត្រ ដែលត្រូវប្រគល់អោយសមាជិកទទួល ក៏ប៉ុន្តែមិនបានទទួលយកដោយសារតែ ការមិនបានចូលរួមក្នុងគ្រាផាត់ទាត់ ឬត្រូវបានផ្អាកមិនអោយចូលរួម ដោយសារការមកដល់យឺតក្នុងថ្ងៃនោះ ត្រូវចាត់ទុកថាបានប្រគល់នៅថ្ងៃនោះ ដើម្បីសំណួមពរទូទាត់និងបង្វិលវិញទាន់ពេលនូវមូលប្បទានប័ត្រមិនទូទាត់ ។

ប្រការ ១៣ : សមាជិកទទួលត្រូវ ៖

១-បញ្ជាក់នូវការយល់ព្រមទទួល (Certify Acceptance )

សមាជិកទទួល ត្រូវចុះហត្ថលេខា លើឡាប់ចំលងនៃតារាង PPCOO1 ដើម្បីទទួលស្គាល់ការទទួលមូលប្បទានប័ត្រនៅសភាផាត់ទាត់ ។ សមាជិកទទួលនីមួយៗ ត្រូវចុះហត្ថលេខាលើច្បាប់ចំលងនៃតារាង PPCOO2 ដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា ដើម្បីទទួលស្គាល់នូវចំនួនទឹកប្រាក់ត្រូវចុះឥណពន្ធ ឬឥណទានក្នុងគណនីផាត់ទាត់របស់ខ្លួន ជាលទ្ធផលនៃគ្រាផាត់ទាត់ ។

២-ទូទាត់សង ឬបង្វិលវិញនូវមូលប្បទានប័ត្រ (Settle for or retum payment)

មូលប្បទានប័ត្រនៅតែជាកម្មសិទ្ធិរបស់សមាជិកប្រគល់រហូតដល់ត្រូវបានទូទាត់សងឬត្រូវបានបង្វិលវិញ ។

សមាជិកទទួលកាន់កាប់មូលប្បទានប័ត្រជាការផ្ញើទុក (In trust) រហូតដល់គេបានទទួលឥណទានពីបហារ៉ក (Drawer) នៃមូលប្បទានប័ត្រ ដោយចុះចូលគណនីរបស់អតិថិជនខ្លួន ។ សមាជិកទទួលត្រូវមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីផាត់ទាត់របស់ខ្លួននៅធនាគារជាតិនៃកម្ពុជា ដើម្បីទូទាត់កាតព្វកិច្ចប្រចាំថ្ងៃ ។

៣-បង្វិលវិញនូវមូលប្បទានប័ត្រមិនទូទាត់ (Return unpaid or dishonored payments)

ក-បទប្បញ្ញត្តិទូទៅ (General Provision )

មូលប្បទានប័ត្រមិនទូទាត់ឬបដិសេធ ត្រូវបានបង្វិលមកវិញតាមរយៈសភាផាត់ទាត់ ។ សមាជិកទទួលត្រូវបញ្ជាក់អោយច្បាស់លើមូលប្បទានប័ត្របង្វិលវិញនូវមូលហេតុដែលបានព្រមព្រៀង ដូចមានរាយក្នុងឧបសម្ព័ន្ធ ៣ និងឈ្មោះរបស់សមាជិកទទួល ។

ខ-បង្វិលវិញអោយទាន់ពេល (Timely return)

មូលប្បទានប័ត្រដែលត្រូវបង្វិលវិញតាមរយៈសភាផាត់ទាត់ ត្រូវធ្វើការបង្វិលវិញអោយទាន់ពេល ហើយសមាជិកទទួលមិនត្រូវបានបង្ខំអោយទទួលខុសត្រូវចំពោះមូលប្បទានប័ត្រនោះទេ ប្រសិនបើមូលប្បទានប័ត្រនោះត្រូវបានបង្វិលវិញ មិនយឺតជាងម៉ោង ៣:០០រសៀលនៃថ្ងៃផាត់ទាត់ ។

មូលប្បទានប័ត្រ មិនត្រូវបានចាត់ទុកថា ទូទាត់បញ្ចប់ជាមួយនឹងការសងជំរះជាសាច់ប្រាក់ទេ រហូតដល់ក្រោយពេលបិទគ្រាបង្វិលវិញ ។

គ-ការទូទាត់សំរាប់ការបង្វិលវិញ (Settlement for return)

សមាជិកទទួលត្រូវបង្វិលវិញនូវមូលប្បទានប័ត្រ មិនទូទាត់ដែលបានបញ្ជាក់ច្បាស់ថា មូលប្បទានប័ត្រ បង្វិលវិញ (Return item) តាមគំរូស្តង់ដារកំណត់ ។ ចំនួនទឹកប្រាក់ត្រូវបានដកចេញវិញពីក្នុងទឹកប្រាក់ទូទាត់សុទ្ធសំរាប់សមាជិកទទួល (គំរូ PPCOO1) ។

ឃ-ការផុតកំណត់នៃសិទ្ធិបង្វិលវិញ (Expiration of return privilege)

មូលប្បទានប័ត្រអាចមិនទូទាត់និងបង្វិលវិញបានតែពីរលើកប៉ុណ្ណោះ ។ មូលប្បទានប័ត្រដែលនៅតែមិនទូទាត់បន្ទាប់ពីការបដិសេធ (Dishonor) លើកទីពីរត្រូវតែដកចេញពីបណ្តាញនៃសភាផាត់ទាត់ដោយទុកអោយធ្វើបេឡានិច័យផ្ទាល់រវាងធនាគារដែលពាក់ព័ន្ធ ។

៤-ការរក្សាទុកនូវការកត់ត្រា

សមាជិកទទួល ត្រូវរក្សាទុកនូវថាសកុំព្យូទ័រ ឬក្រដាសតារាងនិងវត្ថុសំអាងជាក់ស្តែងផ្សេងៗទៀត ដែលចាំបាច់ ដើម្បីបង្កើតឡើងវិញនូវការកត់ត្រាសំរាប់ប្រតិបត្តិការរបស់សភាផាត់ទាត់សំរាប់រយៈពេលមួយឆ្នាំ ក្រោយកាលបរិច្ឆេទទទួល ។ សមាជិកទទួល មិនស្ថិតក្រោមកាតព្វកិច្ចទេ ប៉ុន្តែអាចជួយសមាជិកប្រគល់ក្នុងការដោះស្រាយតំរូវការស្តីពីប្រតិបត្តិការដែលកើតមានឡើង បន្ទាប់ពីរយៈពេលរក្សាទុកនៃការកត់ត្រាចាំបាច់បានផុតកំណត់ ។

៥-ការបង្វិលវិញនៃមូលប្បទានប័ត្រមិនបានកត់ត្រាក្នុងករណីមានកំហុស

ក្នុងករណីសមាជិកមិនមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីចរន្តរបស់ខ្លួននៅធនាគារជាតិនៃកម្ពុជាសំរាប់ការទូទាត់ប្រចាំថ្ងៃ និងត្រូវបាននាយកដ្ឋានត្រួតពិនិត្យធនាគារប្រកាសថា មានអសាធនភាព ធនាគារជាតិនៃកម្ពុជានឹងត្រូវជូនដំណឹងដល់សមាជិកដទៃ និងទាមទារអោយសមាជិកមិនបានទូទាត់នោះបង្វិលវិញជាបន្ទាន់ នូវមូលប្បទានប័ត្រមិនបានកត់ត្រាក្នុងកម្មសិទ្ធិរបស់ខ្លួន ទៅអោយធនាគារជាតិនៃកម្ពុជា ។ បន្ទាប់មក ធនាគារជាតិនៃកម្ពុជានឹងបង្វិលមូលប្បទានប័ត្រនោះ ទៅអោយសមាជិកដែលប្រគល់ពីដំបូងវិញ ។

## ជំពូកទី ៥

## ការទទួលខុសត្រូវរបស់ធនាគារជាតិ នៃកម្ពុជា

**ប្រការ ១៤ :**

ធនាគារជាតិនៃកម្ពុជា គឺជាសមាជិកមួយនៃសភាផាត់ទាត់ ដែលអាចទទួល និងប្រគល់មូលប្បទានប័ត្រ ដូចគ្នានឹងសមាជិកដទៃសំរាប់សងអោយគេឬទារយកពីគេ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាសំរួលដល់គ្រាផាត់ទាត់ និងទូទាត់គណនីទាំងឡាយក្នុងបញ្ជីរបស់ខ្លួន ដែលបានបើកអោយសមាជិកទាំងអស់ ។

**ប្រការ ១៥ :** ការរៀបចំគំរូ (Preparation or form)

អ្នកដឹកនាំផាត់ទាត់ ត្រូវរៀបចំនូវគំរូ PPCOO2 និង PPCOO3 ដោយឧបករណ៍ អេឡិចត្រូនិច ដូចដែលបានបង្ហាញក្នុងឧបសម្ព័ន្ធ ៥ ដោយបញ្ចូលក្នុងតារាងកិច្ចការ កុំព្យូទ័ររបស់សមាជិក (គំរូ PPCOO1) ពីថាសដែលបានយកមកក្នុងគ្រាផាត់ទាត់ ។

**ប្រការ ១៦ :** ការទូទាត់ (Settlement)

១-ការទូទាត់នឹងត្រូវបានអនុវត្តចប់សព្វគ្រប់នៅថ្ងៃធ្វើការនីមួយៗ ដោយការចុះឥណពន្ធនិងចុះឥណទានគណនីចរន្តរបស់សមាជិកដែលបើកនៅធនាគារជាតិនៃកម្ពុជា ។ នៅពេលដែលចំនួនទឹកប្រាក់សរុបនៃមូលប្បទានប័ត្រប្រគល់លើសចំនួនទឹកប្រាក់សរុបនៃមូលប្បទានប័ត្រទទួល គណនីរបស់សមាជិកនឹងត្រូវចុះឥណទាន ។ នៅពេលដែលចំនួនទឹកប្រាក់សរុប នៃមូលប្បទានប័ត្រទទួល លើសចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រប្រគល់ គណនីរបស់សមាជិកនឹងត្រូវចុះឥណពន្ធ ។ នៅពេលដែលអ្នកដឹកនាំផាត់ទាត់ពិនិត្យឃើញថា គំរូទូទាត់របស់សភាផាត់ទាត់មានតុល្យភាពហើយនោះ អ្នកដឹកនាំផាត់ទាត់ ត្រូវចុះហត្ថលេខាលើច្បាប់ចំលង ឬតារាងបោះពុម្ពចេញនៃគំរូ PPCOO2 របស់សមាជិកនីមួយៗ ទុកជាប្រកាសឥណពន្ធ ឬឥណទាន ក្នុងគណនីចរន្តរបស់សមាជិកនោះ ។ បន្ទាប់មកអ្នកដឹកនាំផាត់ទាត់ត្រូវប្រកាសថា គ្រាផាត់ទាត់ត្រូវបញ្ចប់ ។ សមាជិកណាក៏មិនអាចចាកចេញមុនពេលប្រកាសបញ្ចប់គ្រាផាត់ទាត់បានឡើយ ។

២-ក្នុងករណីដែលសមាជិកទទួលមានមូលនិធិមិនគ្រប់គ្រាន់ក្នុងគណនីចរន្តដើម្បីទូទាត់ សមាជិកនោះមានរយៈពេល២ម៉ោង ដើម្បីសំរបសំរួលមូលនិធិធនាគារផ្សេងមួយទៀត ដើម្បីដាក់បញ្ចូល

ក្នុងគណនីចរន្តរបស់ខ្លួននៅធនាគារជាតិនៃកម្ពុជា ។ នេះគឺជាប្រភពចំបង និងរំពឹងបាននៃមូលនិធិសំរាប់ការទូទាត់ ។

**ប្រការ ១៧ :** សមតុល្យដែលបានតំកល់នៅធនាគារជាតិនៃកម្ពុជា (Balance maintained at NBC)

សមាជិកទាំងអស់ត្រូវអនុញ្ញាតអោយធនាគារជាតិនៃកម្ពុជា ចុះឥណពន្ធលើគណនីចរន្តរបស់ពួកគេ នូវចំនួនទឹកប្រាក់ដែលជាលទ្ធផលសុទ្ធនៃការផាត់ទាត់មូលប្បទានប័ត្រ និងត្រូវតំកល់មូលនិធិក្នុងគណនី ចរន្តទាំងនោះអោយមានគ្រប់គ្រាន់ ដើម្បីចុះឥណពន្ធ ។ ជាវិធានការប្រុងប្រយ័ត្ន ធនាគារជាតិ នៃកម្ពុជា អាចទាមទាអោយធនាគារសមាជិកតំកល់អោយបានគ្រប់គ្រាន់នូវប្រាក់បញ្ញើជារូបិយប័ណ្ណក្នុងគណនីផ្សេង ដើម្បីធានាក្នុងការចុះឥណពន្ធសុទ្ធធំបំផុតដែលកើតមានក្នុងត្រីមាសមុន ។

**ប្រការ ១៨ :** ការទូទាត់មិនបាន (Failure to settle)

១-ប្រសិនបើសមាជិកមិនផ្តល់នូវការធានាចំពោះកាតព្វកិច្ចចុះឥណពន្ធសុទ្ធរបស់ខ្លួន ក្នុងសភាផាត់ទាត់ ក្នុងរយៈពេលអនុញ្ញាត២ម៉ោងនោះទេ អ្នកដឹកនាំផាត់ទាត់នឹងជូនដំណឹង ចំពោះប្រធានសភាផាត់ទាត់ ដែលនឹងកំណត់នូវវិធានការកែលំអ ។ ប្រសិនបើធនាគារជាតិនៃកម្ពុជា បានប្រកាសថាសមាជិកនោះ “មានកំហុស (In default )” ប្រធានសភាផាត់ទាត់នឹងជូនដំណឹងចំពោះសមាជិកដទៃទៀត ។ គ្រាផាត់ទាត់មិនត្រូវបានប្រកាសបិទទេ លើកលែងតែគណនីទាំងអស់ត្រូវបានចុះឥណពន្ធជាស្ថាពរនៅថ្ងៃផាត់ទាត់នោះ ។

២-ក្នុងករណីកំហុសត្រូវបានប្រកាសក្នុងគ្រាផាត់ទាត់ ធនាគារជាតិនៃកម្ពុជាត្រូវធ្វើនិយ័តកម្ម (Unwind) នូវការទូទាត់ ពោលគឺ ចុះបញ្ច្រាសនូវឥណទានដែលបានផ្តល់អោយធនាគារទទួលចំពោះមូលប្បទានប័ត្ររបស់ខ្លួនដែលយកទៅអោយសភាផាត់ទាត់ និងចុះបញ្ច្រាសនូវឥណពន្ធចំពោះមូលប្បទានប័ត្រដែលបានយកដោយធនាគារដទៃ ហើយគណនាជាថ្មីនូវស្ថានភាពសុទ្ធរបស់សមាជិកទាំងអស់ស្របតាមនោះ ។ អ្នកដឹកនាំផាត់ទាត់ត្រូវរៀបចំគំរូជាថ្មី ដើម្បីឆ្លុះបញ្ចាំងនូវស្ថានភាពថ្មីរបស់សមាជិកទាំងអស់ ។

ធនាគារមានកំហុសនឹងមិនត្រូវបានអនុញ្ញាតអោយចូលរួមក្នុងការផាត់ទាត់ទៀតឡើយ ។

**ប្រការ ១៩ :** ព្រំដែននៃការទទួលខុសត្រូវ (Limit of liability)

ធនាគារជាតិនៃកម្ពុជា មិនទទួលខុសត្រូវ និងមិនទទួលសងឡើយ ក្នុងករណីដែលសមាជិកមានការខាតបង់ ក្នុងទំនាក់ទំនងជាមួយសមាជិកសភាផាត់ទាត់ លើកលែងតែក្នុងករណីនៃការធ្វេសប្រហែស និងការដឹកនាំមិនត្រឹមត្រូវរបស់ធនាគារជាតិនៃកម្ពុជាផ្ទាល់ ។ ការតវ៉ាទាំងអស់អំពីការ

បែងចែកមិនត្រឹមត្រូវ ការបង្វិលវិញមិនទាន់ពេល ការខកខានមិនបានបង្វិលវិញនូវមូលប្បទានប័ត្រ កំហុសរបស់សមាជិក ។ល។

ត្រូវតែដោះស្រាយដោយផ្ទាល់រវាងអ្នកចូលរួមទាំងអស់ លើកលែងតែសមាជិកទាំងនោះយល់ព្រមប្រើប្រាស់បញ្ញើរបស់ធនាគារជាតិនៃកម្ពុជាដើម្បីកត់ត្រាប្រតិបត្តិការ ។ ប៉ុន្តែ ធនាគារជាតិនៃកម្ពុជា ត្រូវទទួលខុសត្រូវទៅនឹងខ្លឹមសារ និងល័ក្ខខ័ណ្ឌនៃបទបញ្ជាសំរាប់មូលប្បទានប័ត្ររបស់ខ្លួនផ្ទាល់ដែលបានបញ្ចូលដើម្បីផាត់ទាត់ និងទូទាត់តាមរបៀបដូចគ្នា និងសមាជិកដទៃទៀត ។

## ជំពូកទី ៦

## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ២០ :** ច្បាប់សំរាប់គ្រប់គ្រង (Governing Law)

ប្រតិបត្តិការដែលឋិតនៅក្រោមបទបញ្ជានេះ ត្រូវតែអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ជាផ្សេងៗទៀតរបស់ធនាគារជាតិនៃកម្ពុជា ដែលបានផ្សព្វផ្សាយអោយអនុវត្តនូវគ្រប់ករណី ។

**ប្រការ ២១ :** ល័ក្ខខ័ណ្ឌភាពអាសន្ន (Emergency Conditions)

ការដឹកនាំប្រតិបត្តិការផាត់ទាត់ប្រចាំថ្ងៃ អាចត្រូវពន្យាពេលពេញមួយថ្ងៃធ្វើការ ឬ អាចត្រូវលើកទៅថ្ងៃបន្ទាប់ ក្នុងករណីដែលសមាជិកមិនមានលទ្ធភាពអាចចូលរួមបាន ដោយសារតែមានភាពអាសន្ន ដូចជាអាកាសធាតុ ការដាច់ចរន្តអគ្គិសនី ទូរគមនាគមន៍ ការចលាចលផ្សេងៗក្នុងទីក្រុង ឬក្នុងប្រទេស ។ ក្នុងកាលៈទេសៈនេះ ធនាគារជាតិនៃកម្ពុជានឹងផ្តល់ការណែនាំជាក់លាក់ ចំពោះសមាជិកទាំងអស់ទាក់ទងនឹងនីតិវិធីសំរាប់អនុវត្តក្នុងការផាត់ទាត់ ឬត្រូវបង្វិលវិញ ។ ទោះយ៉ាងណាក្តីសមាជិកនិមួយៗ គួរដោះស្រាយតាមលទ្ធភាពរបស់ខ្លួនចំពោះការរំខាននោះ និងត្រូវទទួលខុសត្រូវក្នុងការរក្សាគំរោងការ និងទីកន្លែងដំណើរការដោយមានសំភារៈបរិក្ខារចាំបាច់ដើម្បីបន្តប្រតិបត្តិការសំរាប់រយៈពេល បន្ទាន់ៗ ។

**ប្រការ ២២ :** អំពីស្ថិតិ (Statistics)

ធនាគារជាតិនៃកម្ពុជាត្រូវចងក្រងនិងផ្សព្វផ្សាយនូវស្ថិតិប្រចាំខែ ស្តីពីចំនួននិងទឹកប្រាក់នៃមូលប្បទានប័ត្រដែលបានផាត់ទាត់ប្រចាំថ្ងៃពេញមួយខែ ដោយបញ្ចូលពត៌មាន ស្តីពីមូលប្បទានប័ត្របង្វិលវិញ (មូលប្បទានប័ត្រមិនទូទាត់) ។ លំដាប់លំដោយ នៃស្ថិតិត្រូវប្រៀបធៀបមធ្យមប្រចាំខែសំរាប់ ឆ្នាំនេះ និងឆ្នាំមុន ។

ពត៌មាន ស្ដីពីការផាត់ទាត់របស់ធនាគារសមាជិកនីមួយៗ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេ លើកលែងតែចំពោះធនាគារសាមី ។

ប្រការ ២៣ :

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ២៤ :

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាសមាជិកសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជារៀល ត្រូវអនុវត្តនូវខ្លឹមសារនៃប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ២៥ :

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០០

ទេសាភិបាល

ហត្ថលេខានិងត្រា

ជា ចាន់តូ

★★★

ឧបសម្ព័ន្ធ ១-ក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

====

**ពាក្យសុំចូលជាសមាជិកសភាផាត់ទាត់**

---------

ឈ្មោះអ្នកសុំ : ..............................................................................................

ឋានៈ ..............................................................................................

អាសយដ្ឋាន : ..............................................................................................

អាសយដ្ឋានប្រៃសណីយ៍ :..............................................................................

ទូរស័ព្ទ : ..............................................................................................

ជូនចំពោះ លោកប្រធានសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល

ក្រោយពីបានស្វែងយល់ ប្រកាសស្តីពី សភាផាត់ទាត់មូល្បទានប័ត្រចារឹកជាប្រាក់រៀល លេខ.......... ចុះថ្ងៃទី...... ខែ........ ឆ្នាំ ........... និងដើម្បីសំរួលដល់ការប្រើប្រាស់មូលប្បទានប័ត្ររវាង ធនាគារយើងខ្ញុំ និងធនាគារដទៃទៀតក្នុងទីក្រុងភ្នំពេញ

យើងខ្ញុំសុំស្នើលោកប្រធានសភាផាត់ទាត់ មេត្តាពិនិត្យ និងសំរេចអោយធនាគារយើងខ្ញុំ បានចូលជាសមាជិក នៃសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល ដោយអនុគ្រោះ ។

សូមជូនភ្ជាប់ជាមួយនូវ ៖

-ច្បាប់ថតចម្លងនៃអាជ្ញាប័ណ្ណធ្វើអាជីវកម្មធនាគារ ១ច្បាប់

-លិខិតឧទ្ទេសនាម និងគំរូហត្ថលេខា ៣ច្បាប់

យើងខ្ញុំសន្យាថា និងគោរព អនុវត្តនូវខ្លឹមសារប្រកាសខាងលើដោយម៉ឺងម៉ាត់ ។

សូមលោកប្រធានទទួលនូវការគោរពដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ

ភ្នំពេញ,ថ្ងៃទី ......... ខែ ..............ឆ្នាំ ២០០...

ហត្ថលេខា

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធ ១-ខ

**ធនាគារ .........**

សូមឧទ្ទេសមាននូវឈ្មោះ និងគំរូហត្ថលេខារបស់លោក-លោកស្រី ក្នុងធនាគារយើងខ្ញុំ ដែលមានសិទ្ធិចុះហត្ថលេខាជាផ្លូវការលើលិខិតយុត្តិការ និងសំបុត្រស្នាមផាត់ទាត់របស់ធនាគារយើងខ្ញុំ នៅធនាគារជាតិនៃកម្ពុជា ដើម្បីបំពេញការងារសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល ។

ក/-គណៈកម្មាធិការសភាផាត់ទាត់ :

| | | |
|---|---|---|
| នាយកធនាគារ<br>ឈ្មោះ .............................. | | |
| តំណាងទទួលសិទ្ធិ<br>ឋានៈ..................................<br>ឈ្មោះ ................................ | | |

ខ/-តំណាងចូលរួមគ្រាផាត់ទាត់ (វត្តមានចាំបាច់ ១រូប) :

| | | |
|---|---|---|
| តំណាង<br>ឋានៈ ..............................<br>ឈ្មោះ ........................... | | |
| តំណាងទទួលសិទ្ធិ<br>ឋានៈ .................................<br>ឈ្មោះ ................................ | | |

ពេលដែលលោក-លោកស្រីខាងលើមានការផ្លាស់ប្ដូរភារកិច្ច យើងខ្ញុំនឹងឧទ្ទេសនាមឈ្មោះ និងគំរូហត្ថលេខាជាថ្មីឡើងវិញ ។

គំរូហត្ថលេខានេះមានប្រសិទ្ធភាពប្រើប្រាស់ចាប់

ពីថ្ងៃទី ............... ដល់ .................. ភ្នំពេញ,ថ្ងៃទី.......ខែ ....... ឆ្នាំ២០០...

ភ្នំពេញ,ថ្ងៃទី ......ខែ ...........ឆ្នាំ ២០០.... ហត្ថលេខា

ប្រធានសភាផាត់ទាត់

ឧបសម្ព័ន្ធ ២

## បញ្ជីរាយនាមសមាជិក

### សមាជាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់រៀល

| លេខរៀង | ឈ្មោះធនាគារ | អក្សរសំគាល់ | លេខអត្តសញ្ញាណ |
|---|---|---|---|
| ១ | ធនាគារជាតិនៃកម្ពុជា | NBC | |
| ២ | រតនាគារជាតិ | NTG | TOO1 |
| ៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | FTB | BOO1 |
| ៤ | ធនាគារ កម្ពុជាពាណិជ្ជចំកាត់ | CCB | BOO3 |
| ៥ | ធនាគារ កម្ពុជាសាធារណៈ ចំកាត់ | CPB | BOO4 |
| ៦ | ធនាគារ កាណាឌីយ៉ា | CNB | BOO5 |
| ៧ | ធនាគារ ក្រុងថៃ | KTB | BOO9 |
| ៨ | ធនាគារ កសិករថៃ | TFB | BO12 |
| ៩ | ធនាគារ ក្រេឌីតអាគ្រីកូលឥណ្ឌូស៊ុយអេស៍ | CAI | BO13 |
| ១០ | ធនាគារ កម្ពុជាអាស៊ី | CAB | BO16 |
| ១១ | សាជីវកម្មធនាគារ សឹង្ហបូរី | SBC | BO18 |
| ១២ | ធនាគារ មេឃបែង | MBB | BO20 |
| ១៣ | ធនាគារ សហពាណិជ្ជ | $SCB_1$ | BO21 |
| ១៤ | ធនាគារ ស្តាន់ដាឆាទើរ៉ែត | $SCB_2$ | BO25 |
| ១៥ | ធនាគារ សហពាណិជ្ជ | UCB | BO26 |
| ១៦ | ធនាគារ ក្រៅប្រទេសទី១ | FOB | BO31 |

ឧបសម្ព័ន្ធ ៣

## មូលហេតុដែលបានព្រមព្រៀងសំរាប់ការបង្វិលវិញនូវមូលប្បទានប័ត្រ

១-សវិធានវត្ថុគ្មាន ឬមិនគ្រប់គ្រាន់
២-សវិធានវត្ថុមិនទាន់បានជំរះ
៣-បញ្ឈប់ការទូទាត់
៤-បុរេបរិច្ឆេទ និងកាលបរិច្ឆេទមិនត្រឹមត្រូវ
៥-ហួសកាលបរិច្ឆេទ (លើសពី ៦ខែ)
៦-ចំនួនទឹកប្រាក់ជាអក្សរ និងជាលេខខុសគ្នា
៧-ខ្វះចំនួនទឹកប្រាក់ជាអក្សរ
៨-ហត្ថលេខារបស់បហារ៉ាកខុសពីគំរូហត្ថលេខា
៩-ខ្វះហត្ថលេខារបស់បហារ៉ាក
១០- ខ្វះហត្ថលេខារបស់បហារ៉ាកចំពោះការផ្លាស់ប្តូរ
១១-មិនចេញផ្សាយតាមគំរូធនាគារ
១២-មូលប្បទានប័ត្រខ្មៅចខ្ទី
១៣-គណនីត្រូវបានបិទ
១៤-គ្មានគណនី
១៥-បហារ៉ាកទទួលមរណភាព
១៦- បហារ៉ាកធនក្ស័យ ត្រូវជំរះបញ្ជី

★★★

ឧបសម្ព័ន្ធ ៤

គំរូ **PPCOO1** : កត់ត្រាមូលប្បទានប័ត្ររបស់ធនាគារនីមួយៗប្រគល់អោយសភាផាត់ទាត់

## សភាផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់រៀល

មូលប្បទានប័ត្រប្រគល់ដោយធនាគារ .................................. ចំពោះធនាគារ .........................

ថ្ងៃទី ..................................

| | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជារៀល | | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជារៀល |
|---|---|---|---|---|---|
| 1 | | | 35 | | |
| 2 | | | 36 | | |
| 3 | | | 37 | | |

| | | | | | |
|---|---|---|---|---|---|
| 4 | | | 38 | | |
| 5 | | | 39 | | |
| 6 | | | 40 | | |
| 7 | | | 41 | | |
| 8 | | | 42 | | |
| 9 | | | 43 | | |
| 10 | | | 44 | | |
| 11 | | | 45 | | |
| 12 | | | 46 | | |
| 13 | | | 47 | | |
| 14 | | | 48 | | |
| 15 | | | 49 | | |
| 16 | | | 50 | | |
| 17 | | | 51 | | |
| 18 | | | 52 | | |
| 19 | | | 53 | | |
| 20 | | | 54 | | |
| 21 | | | | | |
| 22 | | | បូកសរុបមូលប្បទានប័ត្រថ្មី | | |
| 23 | | | | | |
| 24 | | | មូលប្បទានប័ត្របង្វិលវិញ | | |
| 25 | | | | | |
| 26 | | | | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជារៀល |
| 27 | | | 1 | | |
| 28 | | | 2 | | |
| 29 | | | 3 | | |
| 30 | | | 4 | | |
| 31 | | | 5 | | |
| 32 | | | 6 | | |
| 33 | | | 7 | | |
| 34 | | | 8 | | |
| | សរុប : | | សរុប មូលប្បទានប័ត្របង្វិលវិញ | | |
| | | សរុបមូលប្បទានប័ត្រថ្មី និងមូលប្បទានប័ត្របង្វិល វិញ | | | |

សំរាប់ប្រើប្រាស់ក្នុងសភាផាត់ទាត់

ហត្ថលេខា ...............

## សភាផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់រៀល

សំរង់មូលប្បទានប័ត្រចារឹកជារៀលមិនអាចទូទាត់បាន

មូលប្បទានប័ត្រ នៃគ្រាផាត់ទាត់ ថ្ងៃទី ..............................

ពីធនាគារ ............................................................

ចំពោះធនាគារ ........................................................

សំរាប់គ្រាផាត់ទាត់ថ្ងៃទី ...............................................

| លេខរៀង | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជារៀល |
|---|---|---|
| | | |
| សរុប : | | |

មូលប្បទានប័ត្រទាំងនេះនឹងត្រូវបានរាយរាប់ក្នុងគំរូ PPCOO1 នៃគ្រាផាត់ទាត់ថ្ងៃទី ..........
សំរាប់មូលប្បទានប័ត្រមិនអាចទូទាត់ ត្រូវបង្វិលវិញ ។

ហត្ថលេខា “ធនាគារប្រគល់”..................

ហត្ថលេខា “ធនាគារទទួល”..................

គំរូ **PPCOO2** : កត់ត្រាសង្ខេបតាមធនាគារនូវមូលប្បទានប័ត្របានប្រគល់អោយសភាផាត់ទាត់

### សភាផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់រៀល

មូលប្បទានប័ត្រប្រគល់ដោយ............“ឈ្មោះធនាគារ” ឥណពន្ធគណនី.............

នៅ............ ម៉ោង”នាគ្រាផាត់ទាត់ ..........“កាលបរិច្ឆេទ” ឥណពន្ធគណនី.............

| លរ | លេខសំគាល់ធនាគារ | ធនាគារ | មូលប្បទានប័ត្រប្រគល់ “សវិធានវត្ថុត្រូវទទួល” | ចំនួន | មូលប្បទានប័ត្រទទួល “សវិធានវត្ថុត្រូវសង ធនាគារដទៃ” | ចំ នួន | ចំនួនទឹកប្រាក់ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ត្រូវទទួល | ត្រូវសង |
| 1 | | | | | | | | |
| 2 | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 3 | | | | | | | | |
| 4 | | | | | | | | |
| 5 | | | | | | | | |
| 6 | | | | | | | | |
| 7 | | | | | | | | |
| 8 | | | | | | | | |
| 9 | | | | | | | | |
| 10 | | | | | | | | |
| 11 | | | | | | | | |
| 12 | | | | | | | | |
| 13 | | | | | | | | |
| 14 | | | | | | | | |
| 15 | | | | | | | | |
| 16 | | | | | | | | |
| | សរុប : | | | | | | | |

ហត្ថលេខា ..........................“ធនាគារប្រគល់ឬទទួល”

ហត្ថលេខា ..........................“ធនាគារជាតិនៃកម្ពុជា”

★★★

គំរូ **PPCOO3** : កត់ត្រានូវលទ្ធផលផាត់ទាត់សរុបតាមធនាគារនីមួយៗ

សភាផាត់ទាត់មូលប្បទានប័ត្រចរាចរជាប្រាក់រៀល

នៅ............ ម៉ោង គ្រាផាត់ទាត់ .......... កាលបរិច្ឆេទ ផលពន្ធគណនី..............

| លរ | លេខសំគាល់ធនាគារ | ធនាគារ | “សមិធានវត្ថុត្រូវសងធនាគារដទៃ” | ចំនួន | “សមិធានវត្ថុត្រូវទទួលធនាគារដទៃ” | ចំ នួន | ចំនួនទឹកប្រាក់ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ត្រូវទទួល | ត្រូវសង |
| 1 | | | | | | | | |
| 2 | | | | | | | | |
| 3 | | | | | | | | |
| 4 | | | | | | | | |
| 5 | | | | | | | | |
| 6 | | | | | | | | |
| 7 | | | | | | | | |
| 8 | | | | | | | | |
| 9 | | | | | | | | |
| 10 | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 11 | | | | | | | | |
| 12 | | | | | | | | |
| 13 | | | | | | | | |
| 14 | | | | | | | | |
| 15 | | | | | | | | |
| 16 | | | | | | | | |
| | សរុប : | | | | | | | |

ហត្ថលេខា ..........................“ធនាគារជាតិនៃកម្ពុជា”

****

**